រ៉ុំ - មាវឌី
សាស្ត្រាចារ្យភាសាខ្មែរ

លោកញ៉ុកថែម និង លាងហាប់អាន
ពិនិត្យ និងកែសម្រួល

# អត្ថបទវណ្ណ៌

រឿង

# ក្រុងសុភមិត្រ

ថ្នាក់ទី២ និងទី១ចំនើប

រ៉ុ.11

បណ្ណាគារ ពន្លឺអក្សរសាស្ត្រ
១៣៨-វិថីព្រះបាទសីហនុ ភ្នំពេញ

22

ន.ន.៥៩៨-៣-១៣-

# កម្មវិធីសិក្សាថ្នាក់ទី ២ និង ទី ១ ទំនើប

# រឿង

# ក្រុងសុភមិត្រ

លេខចុះ 808

អត្ថាធិប្បាយពន្យល់

ដោយ

អ៊ុំ-មាររឌ្ឍី

សាស្ត្រាចារ្យភាសាខ្មែរ

ក្រោមការពិនិត្យ និង ការណែនាំ

របស់

លោក ញ៉ុក-ថែម និង លោក លាង ហាប់អាន

សាស្ត្រាចារ្យនៃមហាវិទ្យាល័យអក្សរសាស្ត្រ

និងវិទ្យាស្ថានជាតិគរុកោសល្យ

ផ្សាយចេញពី

បណ្ណាគារ ពន្លឺអក្សរសាស្ត្រ លេខ ១៣៨ វិថីព្រះបាទសីហនុ

ភ្នំពេញ ឆ្នាំ ១៩៦៣

# អារម្ភកថា

សៀវភៅសិក្សា - អត្ថាធិប្បាយ - ពន្យល់ រឿងក្រុងសុភមិត្រនេះ ពុំមែនជាស្នាដៃយ៉ាងឯក ក្នុងការសិក្សាស្រាវជ្រាវរបស់ខ្ញុំឡើយ គឺគ្រាន់តែជាយោបល់ក្នុងការផ្តល់នូវគំនិតមួយ ដ៏សួចស្តួចតែប៉ុណ្ណោះទេ ។ ទោះជាមានឧបសគ្គមកពាំងពារខ្លះ ៗ ក៏ដោយ ក៏ខ្ញុំខំពុះពារសិក្សាស្រាវជ្រាវប្រមែប្រមូលនូវឯកសារនិងមតិផ្សេង ៗ មកបង្កើតជាសៀវភៅសិក្សា-អត្ថាធិប្បាយ-ពន្យល់,, នេះ ដើម្បីគ្រាន់តែជាជំនួយមតិ ឬ ស្មារតី, ដល់អស់លោកអ្នកនិងមិត្ត ឬចំពោះអ្នកសិក្សាកាម, មួយផ្នែកតែប៉ុណ្ណោះ ។

ម្យ៉ាងទៀតសៀវភៅនេះ គ្រាន់តែជាលទ្ធផលនៃការពិសោធន៍របស់ខ្ញុំ ក្នុងការសិក្សាស្រាវជ្រាវអំពីអក្សរសិល្ប៍ជាតិៗ ដូចនេះ ខ្ញុំពុំមែនជាអ្នកប្រាជ្ញ ឬជាអ្នកនិពន្ធអក្សរសិល្ប៍ឡើយៗ ឯការខុសឆ្គង, ការបាទនិងដោះស្រាយបញ្ហាសោតទៀត ក៏តែងតែមានខ្វះខាតនិងពុំសមរម្យខ្លះ ៗ ជាមិនខាន ។ តែខ្ញុំសង្ឃឹម

ហើយនឹងរង់ចាំជានិច្ចទទួលនូវការរិះគន់គ្រប់បែបគ្រប់យ៉ាង ក្នុងការផ្តល់នូវមតិខ្លះៗទៀត អំពីសំណាក់អស់លោកអ្នក-មិត្ត និងអំពីសំណាក់អស់លោកអ្នកកវីនិពន្ធអក្សរសិល្ប៍ទាំងឡាយផង ។

ព្រោះថាគោលបំណងធំបំផុតរបស់ខ្ញុំ គឺគ្មានអ្វីក្រៅអំពីការចង់លើកដំកើងតម្លៃនៃអក្សរសិល្ប៍ជាតិយើងនេះទេ ។

ម្យ៉ាងទៀត ខ្ញុំសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក ញ៉ុក-ថែម និងលោក ឈាង-ហាប់អាន ដែលបានចំណាយពេលដ៏ថ្លៃថ្លារបស់លោក និងមិនខ្លាចនឿយហត់ក្នុងការជួយផ្តល់នូវមតិខ្លះៗ និងជួយពិនិត្យកែនូវសៀវភៅនេះដោយត្រួសៗ ដើម្បីធ្វើឲ្យការអត្ថាធិប្បាយពន្យល់រឿងសុភមិត្រនេះ កាន់តែសមរម្យថែមទៀត ។

ជាពិសេស ខ្ញុំសូមថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់ចំពោះលោក តាន់-ហ៊ិនសាត់ អគ្គនាយកនៃមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ ដែលលោកបានបង្ហាត់បង្រៀនខ្ញុំ

ទីងទិសៀតសាស្ត្រាចារ្យខាងភាសាខ្មែរទូទៅ ដោយគ្មានសំចៃកម្លាំង ដើម្បីណែនាំយើងខ្ញុំឲ្យចេះគួរយល់នូវរបៀបសិក្សាស្រាវជ្រាវអត្ថបទនីមួយ ៗ ខាងផ្នែកអក្សរសិល្ប៍ខ្មែរ ។

អាស្រ័យហេតុនេះ ខ្ញុំជឿជាក់ថា ៖ អត្ថបទវិជ្ជា „រឿងក្រុងសុភមិត្រ„ នេះជាវិភាគទានមួយទៀត ដែលសម្រាប់ផ្តល់នូវមតិក្នុងការដោះស្រាយ ទីងជាពត៌មានខ្លះ ៗ ចំពោះអស់លោកអ្នកនឹងមិត្ត ក្នុងការស្រាវជ្រាវផ្នែកអក្សរសិល្ប៍យើងនេះ ។

ភ្នំពេញ ថ្ងៃ ២០ កុម្ភៈ ១៩៦៣

អ៊ុំ - ម៉ាឌី

# សេចក្ដីសង្កេតរបស់លោក

សាស្ត្រាចារ្យ លាង-ហាប់អាន

ក្រោយដែលបានពិនិត្យកែសម្រួលនូវពាក្យពេចន៍ ឃ្លា ប្រយោគ និងរបៀបរៀងបែបផែនអត្ថបទឲ្យមានរបៀបបែបបទ ខ្ញុំយល់ថា : សៀវភៅរបស់លោកជាដំបូងនេះ ពិតជាសមរម្យច្រើន, ខាងបច្ចេកទេស ពន្យល់ អត្ថាធិប្បាយ ត្រូវទៅតាមវិធីសាស្ត្រ ពន្យល់អត្ថបទរឿង, និងទាំងខាងការបញ្ចេញគោលគំនិត មតិ និងយោបល់, ស្របទៅតាមបញ្ហាចោទ និងដោះស្រាយខាងអត្ថន័យ អត្ថរូប និងអត្ថរសនៃរឿងក្រងសុភមិត្រនេះហើយ ។

ក្បួនជំនួយដែលរៀបរៀងដោយអ្នកមានការអប់រំជិតដល់មានសញ្ញាបត្រ និងបច្ចេកទេសត្រឹមត្រូវក្នុងមុខវិជ្ជាខាងភាសាខ្មែរដូចរូបលោក នេះ, ពិតជាផ្ដល់នូវប្រយោជន៍ជាគំរូច្រើនចំ

ពោះអស់លោកសាស្ត្រាចារ្យ សិស្សានុសិស្ស ដែលស្រេក
ស្រះទេញក្នុងការសិក្សាអក្សរសិល្ប៍ជាតិជាប្រាកដ ។

ភ្នំពេញ ថ្ងៃទី ១៧ កុម្ភៈ ២៥០៥ / ១៩៦១

លាង ហាប់អាន

(សាស្ត្រាចារ្យខាងភាសាខ្មែរ)

# តារាងកែពាក្យខុស

| ទំព័រ | បន្ទាត់ | ពាក្យខុស | មើលថា |
|---|---|---|---|
| ១ | ទី ៨ | អក្សរសិល្ប | អក្សរសិល្ប៍ |
| ១៨ | — ៤ | ទ៌ព | ទ័ព |
| ១៩ | — ៤ | មត្តា | មេត្តា |
| — | — ៦ | សន្យ | សន្យំ |
| ២៩ | — ១៤ | ឃីញ | ឃើញ |
| ៣៣ | — ៩ | តក្កសីលា | តក្កសិលា |
| ៣៤ | — ៣ | បុស្សរថ | បុស្សរថ |
| — | — ៨ | ផ្សង ៗ | ផ្សេង ៗ |
| — | — ១២ | វេសន្តរ | វេស្សន្តរ |
| — | — ១៣ | បំពោះព្រះអង្គ | ព្រោះព្រះអង្គ- |
| ៣៦ | — [illegible] | ប្រទក្សណ | ប្រទក្សិណ |
| ៤០ | ៣ | តាមមតិបែបគេទៅ | តាមមត់ពីបែបគេទៅ |
| ៤២ | — ៩ | គំ | កំ |

| ទំព័រ | បន្ទាត់ | ពាក្យខុស | មើលថា |
|---|---|---|---|
| ៤៨ | ទី ៦ | ក្ទន | ក្ទង |
| ៥៦ | – ៨ | ឲមារវិធី : | ឲបមានវិធី– |
| ៦០ | – ៥ | សម្ដេចធំពីកោះ | សម្ដេចដ៏ពីកោះ |
| ៦២ | ១០ | ប – ស, ន្ទូហរិធ៍ | ប – សន្ទូហរិធ៍ |
| ៦៥ | – ៥ | វិសេសសិល្បរម្មណត្តសេ | វិសេស សិល្បរម្មណសេ |
| – | - | ប្រសាទសិល្បរម្មណទ្ធ | សោកសិល្បរម្មណត្ត |

# រឿងក្រុងសុភមិត្រ

## អត្ថន័យ

## និទានន័យ

### ក- ប្រភេទ និង ប្រភព

#### ១- ប្រភេទអត្ថបទ

រឿងក្រុងសុភមិត្រ គឺជារឿងទី ៩ ក្នុងរឿងបញ្ញាសជាតក ដែលជារឿង ៥០ ជាតក៍ និយាយអំពីកំណើតពោធិសត្វក្នុងអតីតជាតិនានា (មានជារឿងសាស្ត្រាល្បែងក្តី ដូចជារឿងព្រះសុធន សព្វសិទ្ធិ សុភមិត្រ វរវង្ស សុរវង្ស ។ល។ ជាដើម) ។

ចលនាអក្សរសិល្បផ្នែកនេះ បានផ្អែកទៅលើទ្រឹស្តីពុទ្ធនិយម ហើយកើតឡើងនៅសម័យក្រោយអង្គរ ។ ដែលហៅថាជាតក

នោះ គឺជាកម្រងនៃរឿងការរបស់ព្រះពុទ្ធ កាលពីអតីតជាតិ ហើយដែលបានសំដែងអំពីសកម្មភាពរបស់ព្រះអង្គ ខាងផ្លូវមនុស្សធម៌ សច្ចៈ សុចរិត យុត្តិធម៌ មានព្រះទ័យសប្បុរសចំពោះមនុស្សសត្វទូទៅ ។

ពិតមែនតែរឿងបញ្ញាសជាតកមានឥទ្ធិពលចេញមកអំពីពុទ្ធនិយមក៏ដោយ ក៏ប៉ុន្តែរឿងនេះក៏អាចទទួលនូវឥទ្ធិពលមនុស្សនិយម ឬព្រាហ្មណនិយមខ្លះ ៗ ដែរ ។

រឿងជាតកដែលថិតនៅលើមូលដ្ឋានពុទ្ធនិយម តែងតែប្រកបទៅដោយរបៀបរៀបរឿងឡើង ៣ យ៉ាងគឺ ៖

១– សេចក្តីផ្តើមរឿង : ដំណាលពីអតីត . . .

២– ដំណើររឿង : សកម្មភាពផ្សេង ៗ . . .

៣– សេចក្តីបញ្ចប់ដោយការសជាតិ . . .

**២– អ្នកនិពន្ធ :**

គួរឲ្យស្តាយជាពន់ពេក ដោយនៅពេលដែលយើង

សរសេរ ទំនងធ្វើសេចក្ដីអធិប្បាយនៃរឿង យើងពុំបានដឹងច្បាស់នូវជីវប្រវត្តិរបស់អ្នកនិពន្ធ ។ តែយើងគ្រាន់តែដឹងថារឿងសុភមិត្រនេះ លោកអ្នកឧកញ៉ា គោសាធិបតី "កៅ" ជាចាងហ្វាងក្រុមព្រះឃ្លាំងមណីរ័តន៍ បានតែងដោយប្រែពីភាសាបាលី រៀបរៀងមកជាភាសាជាតិបែបកំណាព្យសាស្ត្រល្បើកក្នុង គ.ស. ១៧៩៨ ហើយមានចំនួន ៣ ខ្សែ ។ (រឿងនេះក្រុមពុទ្ធសាសនបណ្ឌិត្យបានពិនិត្យបោះពុម្ពផ្សាយ) ។

៣– កាលបរិច្ឆេទ :

គឺជារឿងព្រេងដែលមានដំណាលមកពីបុរាណថា ៖ ព្រះសង្ឃនៅស្រុក ឈៀងម៉ៃ ១ អង្គបានបេះចាំហើយតែងជាមគធៈភាសា រួមទាំងអស់ ៥០ រឿង ក្នុង ព.ស. ២០០០ ដល់ ២២០០ ហៅថាគម្ពីរបញ្ញាសជាតក ហើយរឿងនេះមាននៅក្នុងប្រទេសខ្មែរ លាវ និងភូមាប៉ុណ្ណោះ ក្រៅពីនោះគ្មាន ។

គួរកត់សំគាល់ទៀតថា : លោកអ្នកស្រុកញ៉ាគោសាធិបតី „ គៅ " នៃរឿងក្រុងសុកមិត្រនេះ ក្នុងរាជ្យព្រះបាទសម្តេចព្រះអង្គ ច័ន្ទ ពី គ.ស. ១៧៩៦–១៨៣៤ ។ ព្រះរាជាអង្គនេះ ជាព្រះរាជបុត្រច្បងនៃព្រះបាទ អង្គ អេង ។

១– សង្កមដ្ឋាន :

ក– សង្កមប្រវត្តិ :

តាមកាលបរិច្ឆេទនៃរឿង (គ.ស. ១៧៩៨) យើងឃើញថា : រឿងក្រុងសុកមិត្រសរសេរឡើង ក្នុងសម័យកាលនៃការគ្រប់គ្រងនៃព្រះបាទសម្តេចព្រះអង្គ ច័ន្ទ ។ តែនៅពេលនោះ ព្រះរាជាអង្គនេះ ត្រូវបិតនៅក្រោមរាជានុសិទ្ធិរបស់លោក តេន ( Ten ) ។ លុះព្រះជន្មបាន ១៦ ព្រះវស្សា គេក៏នាំព្រះរាជាអង្គនេះធ្វើរាជាភិសេកនៅឯបាងកក ក្រោមអធិបតីភាពនៃព្រះចៅសៀម ។

គឺនៅក្នុងបតវត្សនេះហើយ ដែលប្រទេសកម្ពុជា ត្រូវទទួលគ្រោះថ្នាក់ដោយចំបាំងរាំងជុលយ៉ាងធំ មានការកាប់សម្លាប់គ្នាដោយសៀមនិងយួនរាំបានចូលមកលុកលុយ ធ្វើចំបាំងដណ្តើមទឹកដីរបស់ខ្មែរ ហើយមានការបែកបាក់សាមគ្គីរវាងខ្មែរនិងខ្មែរផង ។ អ្នកខ្លះចូលសៀម ខ្លះចូលយួនដើម្បីច្បាំងនឹងគ្នាឯង មានការក្បត់និងគ្នាឯងទៀតផង ។

ដូច្នេះយើញថា: សម័យនោះប្រទេសយើងពុំទាន់មាន សភាពស្រួល សម្បូរ សប្បាយ ត្រជាក់ត្រជុំ មូលមិត្តគ្នានៅឡើយទេ ។

៦- សង្គមបញ្ញា :

ដោយការកើតបលាចលមានចំបាំងរាំងជុលពីក្រៅប្រទេស និងទាំងក្នុងប្រទេស ដូច្នេះហើយដែលបង្កើតជាបញ្ហាចោទឡើង ចំពោះអ្នកការិនិពន្ធរឿងនេះ ៗ បានសេចក្ដីថា : ដោយចង់ឲយ

សង្គ្រាមទាំងនោះលោយលែងទៅវិញ ដើម្បីបង្កើតឱ្យសន្តិភាព ទើបលោកឧកញ៉ាគោសាធិបតី កៅ និពន្ធរឿងនេះឡើង ដើម្បីទុកជានិមិត្តរូបនៃសេចក្ដីសង្ឃឹមរបស់លោក ។

៣- សត្តមបរិយាកាស :

ដូចជាយើងបានពោលរួចមកហើយ សេចក្ដីសង្ឃឹមក្នុងការបង្កើតឱ្យសន្តិភាព គង់តែបិតដុះជាប់នឹងអារម្មណ៍របស់លោកឧកញ៉ាគោសាធិបតី កៅ ជាដរាប ។

អាស្រ័យហេតុនេះ បានជាសេចក្ដីសង្ឃឹមទាំងនោះដែលជាបរិយាកាសនៃមូលដ្ឋានបង្កើតនឹងណែនាំឱ្យលោកតែងនិពន្ធរឿងនេះឡើង ។

រូបគយ

១- តួអង្គ :

ក- ឈ្មោះ-មុខងារ :

| ល | នាមតួអង្គ | ភេទ | វង្សត្រកូលឋានៈ |
|---|---|---|---|
| ១ | ព្រះបាទក្រុងសុភមិត្រ | ចម្យាកខ្វីវត្ត | ជាស្តេចសោយរាជ្យ |
| ២ | ព្រះនាងកេសរី | — | អគ្គមហេសីព្រះបាទសុភមិត្រ |
| ៣ | ជ័យសែន ជ័យទត្ត | — | ជាបុត្រព្រះបាទសុភមិត្រ នឹងព្រះនាងកេសរី |
| ៤ | ក្រុងអសុភមិត្រ | — | ជាអនុជព្រះបាទក្រុងសុភមិត្រ |
| ៥ | នាយព្រានមញ្ញ | — | ជាអ្នកថែរក្សាចៅជ័យសែន ជ័យទត្ត |
| ៦ | នាយភេព្រាសាគរ ពាណិជ | — | អ្នករើសយកព្រះនាងកេសរី |

## ១ – លក្ខណៈ

យើងអាចដឹងនឹងឃើញមកហើយនូវតួអង្គជារូប ដែលបិតនៅក្នុងរឿងនេះ តែបើយើងសង្កេតឲ្យបានច្បាស់លាស់បន្តិចទៅ យើងអាចឃើញនូវតួអង្គជាអរូបមួយទៀតដែលជាតួចំនាស់ទីងគ្នាយ៉ាងជាប់ណាត់ៗ គឺអំពើបាប នឹងអំពើបុណ្យៗ

តើគូទំនាស់នេះ មានឯកភាពដែរឬទេ? - យើងដឹងហើយថា ចាប់តាំងពីដើមនៃរឿងរហូតដល់ចប់ គូទំនាស់រវាងបាបនិងបុណ្យ នេះតែងធ្វើដំណើរប្រឆាំងគ្នាជានិច្ចឥតឈប់ឈរ លុះដល់ចប់រឿង ។ ដូច្នេះឃើញថា: គូទំនាស់រវាងបាបនិងបុណ្យនេះ មានឯកភាពដាច់ខាត ។

២- កាល-អាកាស :

ក- ទីកន្លែង :

រឿងក្រុងសុភមិត្រនេះ កើតមានឡើងនៅក្នុងនគរបម្បាកបុរីក្ត - នៅក្នុងព្រៃ - នៅឆ្នេរសមុទ្រ និងនៅឯនគរតក្កសីលា ។

២- ពេលវេលា :

ពេលវេលានៃរឿងនេះ មានរយៈកាលវែងណាស់ ៗ គឺ ចាប់តាំងពីព្រះបាទក្រុងសុភមិត្រត្រូវព្រះអនុជក្បត់ រហូតដល់ចប់ មួយជីវិតរបស់ព្រះអង្គ ។

៣ - វិភាគរឿង និងចលនា :

យើងអាចចែករឿងក្រុងសុភមិត្រនេះជា ៣ ចលនា៖

ក - ចលនាទី ១ : ការក្សត់នៃក្រុងសុភមិត្រ .

ទំព័រ ៣ . . . ទំព័រ ១៣ នៃវគ្គទី ១

« ពីរកាលកញ្ញខក្កខាង . . . គន្លឹកពន្លឺលោក » ។

ខ - ចលនាទី ២ , ការព្រាត់ប្រាសនៃព្រះបាទ
ក្រុងសុភមិត្រ .

(ទំព័រ ១៣ ក្នុងវគ្គ ១ . . . ទំព័រ ១១ វគ្គ ២)

ក្នុងចលនានេះ យើងអាចចែកជា ៣ ខណៈដូចតទៅ :

១ - ទំព័រ ១៣ . . . ដល់ទំព័រ ១៥ វគ្គ ១

ទុក្ខវេទនារបស់ព្រះបាទសុភមិត្រតាមផ្លូវ .

២ - ទំព័រ ១៥ . . . ទំព័រ ២២ វគ្គ ១

ព្រះបាទសុភមិត្រនាំមហេសីឆ្លងសមុទ្រ .

៣ - ពីទំព័រ ២២. . . . ដល់ទំព័រ ២៣ វគ្គ ១

ព្រាត់ល្អួងណោមយ កុមារ (ជ័យសេន—ជ័យទត្ត) ទៅ.

៤–ពីទំព័រ ២៣ . . . .  ដល់ទំព័រ ៣០ ខ្សែ ១

តាមភេត្រាសាគ ពាណិជលោមនាងកេសរី.

៥–ពីទំព័រ ១ ខ្សែ ២ : . .  ដល់ទំព័រ ៨ ខ្សែ ២

សុភមិត្រស្វែងរកបុត្រនឹងមហេសីមិនឃើញ .

៦–ពីទំព័រ ៨ . . ,  ដល់ទំព័រ ១១ ខ្សែ ២ .

ការពិពណ៌នាធម្មជាតិ .

## គ– ចលនាទី ៣ : ការជួបជុំនៃក្សត្រទាំង ៤ អង្គ

(ពីទំព័រ ១១ ខ្សែ ២ . . .  ដល់ចប់) .

ក្នុងចលនាទី ៣ នេះ យើងអាចចែកជាខណៈទៀត ៖

១–ទំព័រ ១១ ខ្សែ ២ . . .  ដល់ទំព័រ ២៣ ខ្សែ ២.

ក្រុងសុភមិត្របានឡើងសោយរាជ្យនៅនគរតក្កសីលា ,

ក- ពិធីផ្សងបុស្សរថ,

ខ–ពិធីផ្ទុំស្ពីចំរើនព្រះជន្មព្រះបាទក្រុងសុភមិត្រ.

២–ពីទំព័រ ២៣ . . .  ដល់ទំព័រ ២៦ ខ្សែ ២'

ព្រានមុជ្ជានាំកុមារទៅថ្វាយក្រុងសុភមិត្រ,

៣–ពីទំព័រ ២៦ . . .  ដល់ទំព័រ ៨ ខ្សែ ៣,

កុមារទៅយាមសំពៅបានជួបមាតា·

ក—គាយភេត្រានាំភស្តុភារទៅថ្វាយព្រះបាទសុភមិត្រ.

ខ- ព្រះនាងកេសនីសោកាល័យដល់បុត្រនឹងស្វាមី,

គ — កុមារនិយាយរៀបរាប់ពីការព្រាត់ប្រាស់មាតាបិតា,

៤— ពីទំព័រ ៨ . . .    ដល់ទំព័រ ១៩ ខ្សែ ៣,

ព្រះបាទក្រុងសុភមិត្រឲ្យពេជ្ឈឃាតនាំកុមារទាំងពីរទៅសម្លាប់,

៥ — ពីទំព័រ ៨ . . .    ដល់ទំព័រ ១៩ ខ្សែ ៣

ការជួបជុំនៃក្សត្រទាំង ៤ អង្គ.

ក— ការសាកសួរនឹងដឹងកុមារជាបុត្រ,

ខ— ព្រះបាទក្រុងសុភមិត្រយាងទៅរកនាងកេសនី,

៦— ពីទំព័រ ១៩ . . .    ចប់,

អំពីការសជាតិ,

## ៣- គាមន័យ .

មុននឹងពោលហើយនឹងដោះស្រាយបញ្ហា    គប្បីយើងធ្វើសេចក្តីសង្ខេបជាមុនសិន ៖

សេចក្តីសង្ខេប ៖

(តាមសៀវភៅព្រះពុទ្ធប្រវត្តិ ដោយពុទ្ធសាសនបណ្ឌិត្យ)

ព្រះបាទ សុភមិត្រ សោយរាជ្យដោយក្ដីក្ដានបុរីមហានគរ ចម្បាតាបុរីរដ្ឋ ជាមួយព្រះអគ្គមហេសីព្រះនាមនាង គោ-សម្ពី ទ្រង់មានព្រះរាជបុត្រ ២ អង្គ ព្រះនាម ជ័យសេន ជាបង និង ជ័យទត្ត ជាប្អូន ។

ព្រះបាទ អសុភមិត្រ ជាព្រះអនុជ កាន់តំណែងជា មហាឧបរាជ ។ ដោយមានចិត្តចង់ប្រណាំងនឹងរាជសម្បត្តិ កើតចិត្តក្បត់ ហើយបានលើកទ័ពទៅឡោមព័ទ្ធមហាប្រាសាទ ដែលជាទីគង់ព្រះបាទក្រុងសុភមិត្រ ភៀសព្រះអង្គចេញចាករាជប្រាសាទជាមួយនឹងមហេសី ព្រមទាំងព្រះរាជបុត្រទាំងពីរ ទៅកាន់ព្រៃ ។

លុះមកដល់ឆ្នេរនេះ ក្រុងសុគមិត្រនឹងមហេសីទ្រង់គក់ស្ដុតខ្លួតសោយសោកជាពន់ពេក ហើយទ្រង់សម្រេចចិត្តនាំមហេសីហែលឆ្លងទៅមុន ទុកបុត្រទាំងពីរនៅប្រចាំឆ្នេរសមុទ្រម្នាង ។ ក្រោយដែលនាំមហេសីហែលឆ្លងទៅ មានព្រានមច្ឆាពីរនាក់ដែរទូកមកឃើញកុមារទាំងពីរ ក៏លោមចាប់យកទៅ ។

ដល់ត្រើយនាយ ក្រុងសុគមិត្រទុកមហេសី ហើយត្រឡប់មករកបុត្រវិញ ។ ពេលនោះមាននាយកេត្រាសារពាណិជ្ជ បើកសំពៅមកឃើញព្រះនាងកេសទីនៅតែម្នាក់ឯង កើតចិត្តប្រតិព័ទ្ធ ក៏ចាប់ដាក់សំពៅយកទៅ ។

ក្រុងសុគមិត្រ ត្រឡប់មកវិញរកបុត្រមិនឃើញ ទ្រង់សោយសោកសង្រេងសន្លប់បាត់ស្មារតី ។ លុះភ្ញាក់ពីសន្លប់វិញ ព្រះអង្គក៏ត្រឡប់ទៅរកមហេសីឯត្រើយម្ខាងវិញ ។ ទ្រង់រក

មហាសីមិនឃើញទៀត ក៏ទ្រង់វិយោគលុះដល់សន្លប់ ៗ លុះដឹងខ្លួនហើយ ក៏ធ្វើដំណើរតែឯកឯងត្រាច់ចរដោយឥតទិសដៅ ៗ គួរកត់សំគាល់ថា ៖ ការព្រាត់ប្រាស់នេះ គឺបណ្ដាលមកអំពីកម្មផលរបស់ព្រះអង្គក្នុងអតីតជាតិ ដោយព្រះអង្គបានយកកូនសត្វសេកឱ្យព្រះរាជបុត្របោចស្លាបលេង ហើយកម្មពៀរវេរានេះឯង តាមមកផ្ដន្ទាព្រះអង្គគ្រប់៥០០ ជាតិ ទើបរួច ។

ព្រះបាទក្រុងសុគមិត្រយាងទៅដល់នគរ តក្កសិលា ហើយ គាប់ជួនព្រះមហាក្សត្រក្នុងនគរនោះទើបសោយទិវង្គត ទៅ ពួកព្រាហ្មណ៍បុរោហិតបានធ្វើពិធីផ្សងបុណ្យរថ ដើម្បីគ្រប់គ្រងនគរ ៗ ក្រុងសុគមិត្រត្រូវពលសេនាមុខមន្ត្រីយាងស្ដេចទៅសោយរាជ្យនៅនគរនោះ ។

ដំណាលអំពីព្រានមច្ឆា ដែលចង់ឲ្យកុមារទាំងពីរមានអនាគតប្រសើរ ក៏នាំយកទៅថ្វាយព្រះបាទក្រុងសុគមិត្រ ៗ ពុំស្គាល់ជាបុត្រទេ ៗ ប៉ុន្តែទ្រង់ទទួលថែរក្សា ហើយស្រឡាញ់

ជួបកូនបង្កើត ។ ចំណែកនាងកេសិនីវិញ ត្រូវនាយកេត្រា នាំទៅដល់នគរតក្កសីលានោះដែរ ហើយបានចូលទៅក្រាបបង្គំគាល់ព្រះបាទសុកមិត្រ ផងលានាយពាណិជ ។ ពេលនោះ ក៏ចាត់ឲ្យកុមារទាំងពីរនៅចាំយាមសំពៅ ដែលជាហេតុនាំឲ្យកុមារជួបនាងកេសិនីជាមាតា ។ ដោយបានជួបគ្នាម្ដាយនឹងកូន ស្រវ៉ាឱបអាឡោះអាល័យដោយក្ដីនឹករឭក ។

ចំណែកពួកកេត្រាទាំងឡាយ ក៏ចោទប្រកាន់ថា កុមារបានស្រឡាញ់ប្រពន្ធនាយសំពៅ ។ ដំណើរនេះបានជ្រាបដល់ទៅព្រះបាទក្រុងសុកមិត្រ ។ ក៏ប្រើឲ្យពេជ្ឈឃាតចាប់កុមារទាំងពីរយកទៅសម្លាប់ ។

ដោយការទូលទាស់របស់ព្រាហ្មណ៍ព្រឹទ្ធាចារ្យ អំពីការយកកុមារទៅសម្លាប់ដោយឥតជំនុំរកហេតុផលជាមុនសិន , ក្រុងសុកមិត្រក៏ប្រើឲ្យអាមាត្យទៅតាមនាំយកកុមារមកវិញ ដើម្បី

សោកស្ដាយ ៗ កុមារទាំងពីរទូលខ្លួនការព្រាត់ប្រាសអំពីឪពុក ទូលនាមមាតាបិតា ៗ ជ្រាបដូច្នោះ ក្រុងសុភមិត្រស្ទុះទៅឱប បុត្រទាំងពីរដោយក្ដីអាណិតអាសូរជាអនេក ។ ក្រោយនោះព្រះបាទក្រុងសុភមិត្របានយាងទៅរកនាងកេសរនីនៅឯសំពៅ ។

បុត្រទាំង ៤ សោយសោកជាខ្លាំង ៗ ទ្រង់ត្រឡប់មកប្រាសាទវិញ ដោយពេញជាសុខក្សេមក្សាន្តរហូតចូលទីវង្គត ។

៤– មូលបញ្ហា ៖

រឿងក្រុងសុភមិត្រ ជារឿងមួយដែលបង្ហាញនូវកម្មពៀរ វេរាពីអតីត ដែលមនុស្សត្រូវទទួលនូវកម្មផលនៅក្នុងបច្ចុប្បន្ន ។ ជាពិសេសអ្នកនិពន្ធចង់បង្ហាញនូវទុក្ខទោសរបស់ បុណ្យ និង បាប នេះឯង ។ បានសេចក្ដីថា ៖ កាលបើមានបញ្ហាពៀរ ឡើងចំពោះគូអង្គណាហើយ គូអង្គនោះពុំអាចបៀសវាងផុត បានឡើយ គឺត្រូវតែទទួល ហើយជាពិសេស ពុំអាចតបត

ប្រឆាំងទៅវិញទៀតផង ។ គោលគំនិតតទៅទៀតគឺ៖ សន្តិភាពៈនេះឯង ដែលអ្នកក៏ទិតខ្ពង់លើកយកមកលាតត្រដាង បង្ហាញក្នុងសម័យកាលនេះ ។

៣- បញ្ហាចោទ និងបញ្ហាដោះស្រាយ៖

គោលមតិសំខាន់ ១ ៖ រឿងក្រុងសុគមិត្រឋិតនៅលើ៖

បលតាទី ១ ៖ ការក្សត់នៃក្រុងអសុគមិត្រ

បលតទី ២ ៖ ការព្រាត់នៃក្រុងសុគមិត្រ

បលតាទី ៣ ៖ ការជួបជុំនៃក្សត្រទាំង ៤ អង្គ ។

## បលតាទី ១

បញ្ហាចោទទី ១៖ ហេតុអ្វីបានជាក្រុងអសុគមិត្រក្សត់?

ការដោះស្រាយ៖ មានប្រភពក្នុងហេតុ ២ យ៉ាងគឺ៖

ហេតុទី ១: គឺដោយសារបាបរបស់ក្រុងសុកមិត្រដែលបានធ្វើអំពីអតីតជាតិ ហើយមកផ្ដាទ់ក្នុងជាតិនេះ ដែលបណ្ដាលឲ្យក្រុងអសុកមិត្រកើតចិត្តខឹងប្រណែននឹងព្រះវៀម ហើយបណ្ដាលឲ្យមានចិត្តក្បត់លើកទ័ពទៅឡោមវាំង ដើម្បីដណ្ដើមយករាជសម្បត្តិ ។

ហេតុទី ២: ក្នុងកាលដែលក្រុងអសុកមិត្រ កើតចិត្តក្បត់ចង់បានរាជសម្បត្តិនោះ បើយើងពិភាក្សាទៅតាមបញ្ហាមនុស្ស យើងអាចបញ្ជាក់បានថា បញ្ហាដែលមាននៅក្នុងលោកយសច្ចៈ ទឹងជាបញ្ហាទាក់ទងទៅនឹងបញ្ហាសង្គមមនុស្ស ។

ហេតុនេះ ក្រុងអសុកមិត្រក៏ដូចជាមនុស្សខ្លះទៀតទាំងអស់ដែរ តែងតែមានចិត្តលោភលន់ឥតឈប់ឈរ ។

បញ្ហាទី ២ — ហេតុអ្វីក៏ព្រះបាទក្រុងសុកមិត្រលះបង់រាជសម្បត្តិទុកឲ្យព្រះអនុជរបស់ព្រះអង្គគ្រប់គ្រងទៅវិញ ។

ការដោះស្រាយ – ចំពោះសំនួរនេះ យើងដោះស្រាយបាន ដូចតទៅ ៖

ក) បើតាមទស្សនពុទ្ធនិយម គួអង្គពោធិសត្វត្រូវតែប្រកប ដោយ មេត្តាករុណា ធ្វើបុណ្យទាន ព្រមទាំងសុខចិត្តលះបង់ ទ្រព្យសម្បត្តិ ប្រពន្ធកូន អាយុជីវិតរបស់ខ្លួនឯងផង ។ ធ្វើ ដូច្នេះ ដើម្បីសន្សំនូវសីលទាន ដើម្បីឲ្យបានត្រាស់ជាព្រះ ពុទ្ធទៅថ្ងៃក្រោយ ។

១) ម្យ៉ាងទៀតដោយព្រះអង្គយល់ឃើញថា: ទ្រព្យសម្បត្តិ យសស័ក្តិនិងរូបសម្បត្តិរបស់យើងនេះ សុទ្ធតែជារបស់អនត្តា កើតមកហើយតែងតែវិនាសទៅវិញ ។

– ដោយយល់ឃើញថា: មានតែសីលទាន ទើបនាំឲ្យព្រះ អង្គរួចពីសេចក្តីទុក្ខបាន ។ ដូចជាព្រះអង្គបានបញ្ជាក់នៅគន្ថ វគ្គទី ១ ទំព័រ ១៣ ថា "ស្តេចគិតថាផ្គតអនិច្ចា រូបំអនិត្តា ឥតខ្លឹមឥតសារសូន្យសោះ ។ សង្ខារបណ្តាលទោសស្មោះ

ឥតត្រើយឥតកោះ ពំនាក់ពំនឹងរួចបាន ។ យន់យល់តែស័ល

នឹងតាន ទៀងទើបនាំប្រាណ រួចចេញពីចកុភផាយ" ។

អាស្រ័យហេតុនេះហើយ បានជាព្រះអង្គពុំព្រមប្រខុស្ត-

កាយតបតនឹងប្អូនវិញ ហើយសុខចិត្តតែដើរចាកចេញពីនគរជា

មួយនឹងភរិយាព្រមទាំងព្រះរាជបុត្រាទៅតាមកម្មផលរបស់ខ្លួន ។

បញ្ហាទី ៣ : ហេតុអ្វីបានជាព្រះបាទក្រុងសុកម៉ត្រមិន

ច្បាំងតតាំងនឹងព្រះអនុជ ?

<u>ការដោះស្រាយ</u> យើងអាចបញ្ជាក់បានថា: ព្រះអង្គមិន

ច្បាំងតទល់នឹងព្រះអនុជព្រោះ ៖

ក - បើតាមប្រភពរឿងវិញ គេបានបញ្ជាក់ឲ្យយើង

ឃើញថា : កាលបើព្រះអង្គច្បាំងតបតវិញទៅនាំឲ្យកើតមាន

មហន្តរាយទៀងក្នុងការធ្វើសង្គ្រាមនោះ គឺព្រះអង្គបារម្ភខ្លាច

ស្លាប់ដល់ប្រជារាស្ត្រទាំងនគរ ដោយសារតែការដណ្តើមរាជ្យ

គ្នានេះ ។ ដូចព្រះអង្គបានបញ្ជាក់ក្នុងវគ្គ ១ ទំព័រ ១៣ ថា៖

“បើយើងតតាំង កងទ័ពចេញច្បាំង ឱយយល់ឬទេ ក្រែងកើតកង្វល់ អម្ពល់សេចក្តី អាសូរប្រណី រាស្ត្រផងទាំងឡាយ ។ នឹងកើតផ្សារក្តៅ ព្រាត់ព្រាសកូនចៅ ហិនហោចខ្ចាត់ខ្ចាយ ស្លុតស្លាប់ស្យូវស្យា ហេតុនេះអញណាយ មិនឱយអន្តរាយ ដល់ជាតិឡើយហោង ”

អាស្រ័យហេតុនេះ ទើបព្រះអង្គសម្រេចព្រះទ័យថា មិនច្បាំងតបវិញឡើយ គឺសុខចិត្តភៀសចាកចេញពីនគរ ចូលទៅនៅក្នុងព្រៃហេមពាន្តវិញ ដើម្បីរកសន្តិភាព ហើយត្រូវតាមគំនិតក្នុងពុទ្ធសាសនាថា “ពៀរមិនអាចរម្ងាប់បានដោយពៀរ” នេះឯង ។

បញ្ហាចោទទី ៤ : អំពីបញ្ហាតួអង្គ

ព្រះបាទក្រុងសុភមិត្រមិនច្បាំងនឹងព្រះអនុជ សុខព្រះទ័យលះបង់រាជសម្បត្តិ ព្រះរាជវាំង ប្រាថ្នាដោះស្រាយរកសន្តិភាព នេះជាលក្ខណៈតួអង្គពោធិសត្វមួយផ្នែកដែរ ។

តែគួរយើងបញ្ជាក់ថា ៖ តួអង្គក្រុងសុភមិត្រមិនមែនជាតួអង្គ

តំណាងសការៈល្អនោះទេ (មិនមែនដូចជាព្រះរាមក្នុងរឿងរាមកេរ្តិ៍ឡើយ) ។ ចំណែកតួអង្គក្រុងអសុកមិត្រ ដែលមានចិត្តក្បត់នឹងព្រះរៀមឯងដូច្នេះ គឺដោយសារអំពើបាបដែលក្រុងសុកមិត្របានធ្វើពីអតីតជាតិ ហើយដែលមកផ្តន្ទាក្នុងជាតិនេះ ។ យើងត្រូវដឹងថា: ក្រុងអសុកមិត្រ ក៏មិនមែនជាតួអង្គដំណាងសការៈអាក្រក់ដែរ ។

យោបល់រួមក្នុងចលនាទី ១:

តាមការសង្កេតទូទៅក្នុងចលនាទី ១ នេះ យើងអាចបញ្ជាក់បានថា ការក្បត់របស់ក្រុងអសុកមិត្រនេះច្រើនតែពឹងផ្អែកទៅលើបញ្ហាកម្មផល របស់ព្រះបាទក្រុងសុកមិត្រតែប៉ុណ្ណោះ ។

X X
X

## បលនាទី ២

**បញ្ហាទី ១ :** ហេតុអ្វីបានជាក្រុងសុកមិត្រត្រូវព្រាត់ប្រាស់មហេសីនិងបុត្រ ។

**ការដោះស្រាយ :** យើងអាចដោះស្រាយបានដូចតទៅនេះ ៖

— ដូចជាយើងបានបញ្ជាក់នៅក្នុងបលនាទី ១ រួចមកហើយ អំពីបញ្ហាដែលជាផលអាក្រក់នាំឲ្យក្រុងសុកមិត្ត ត្រូវវិនាសអំពីនគរ ត្រាច់ចរក្នុងព្រៃព្រឹក្សា ។

ជាពិសេស នៅក្នុងបលនាទី ២ នេះ ផលនៃអំពើបាប ដែលក្លាយមកជាពៀរវេរា ព្រេងវាសនា តាមផ្ដន្ទាទោសក្រុងសុកមិត្រ ហើយដែលក្រុងសុកមិត្រគ្មានសមត្ថភាពនឹងអាចគេចដោះខ្លួនឲ្យផុតពីទណ្ឌកម្មនេះបានឡើយ គឺកម្មពៀរវេរា ព្រេងវាសនា ដែលជាកម្លាំងមួយខ្លាំងក្លាបំផុត (Force fâtâle) ហើយមកផ្ដន្ទាក្រុងសុកមិត្រ ៗ ត្រូវតែទទួលជាដាច់ខាត ។ ដូច

ជាទៅវិញទី ១ ទំព័រ ២១ បានបញ្ជាក់ថា៖ « កម្មឯងពីព្រេងនោះហើយ ធ្វើម្ដេចស្នងគើយ ចៀសបានពុំបាន » ដូច្នេះក្រុងសុភមិត្រដែលត្រូវទំពាសពិនេរ ព្រាត់ប្រាស់ពីមហេសីនិងបុត្រ គឺដោយសារតែធំនាស់រវាំងបុណ្យនិងបាប ដែលក្រុងសុភមិត្របានកសាងពីអតីតជាតិ ។

បញ្ជាក់ :

ក- ការព្រាត់ប្រាស់ក្នុងពុទ្ធនិយម មិនដូចជាការព្រាត់ប្រាស់ក្នុងព្រាហ្មណនិយមឡើយ ។ គឺនៅក្នុងលទ្ធិព្រាហ្មណនិយម ការព្រាត់ប្រាស់កើតមកពីទំនាស់ ការប្រយុទ្ធដោយសការៈល្អ និងសការៈអាក្រក់ ។ ជាពិសេស ដោយការទាក់ទងទៅនឹងជីវភាពមនុស្សនេះឯង ដូចជាព្រះរាមត្រូវព្រាត់នាងសីតា គឺដោយសារការសង៍សឹករបស់ក្រុងរាពណ៍ ។

១- ពិតមែនហើយតែរឿងនេះជារឿងពុទ្ធនិយម តែយើងឃើញថា: ការព្រាត់ប្រាស់របស់ព្រះអង្គព្រះពោធិសត្វនេះ បានបញ្ជាក់ឲ្យមើលឃើញនូវសេចក្តីទុក្ខព្រួយ សោកសង្រេងសង្រែង ដែលមានលក្ខណៈជាមនុស្សសុទ្ធ ៗ ដូចជា :

១)- ក្នុងពេលដែលក្រុងសុភមិត្រ ហៅលង្វងសម្រេចជាមួយនឹងព្រះនាងកេសនី ព្រះអង្គតែងតែនឹករឭកព្រះកជបុត្រទាំងពីរ ៗ ទ្រង់សោយសោកគរលោះអាល័យយ៉ាងខ្លាំង ៗ

២)- នៅពេលដែលព្រះបាទក្រុងសុភមិត្រ ទ្រង់ឃ្លាតអំពីព្រះនាងកេសនី ហៅលត្រឡប់ទៅចម្ងងព្រះកជបុត្រនោះ ព្រះអង្គទ្រង់សោយសោកនឹកយ៉ាងខ្លាំងទៅដល់នាងកេសនី ៗ

៣) នៅពេលដែលនាយគេត្រា មកបង្ខំចាប់ព្រះនាង ទៅ នាងកេសរី យំសោយសោកទឹកភ្នែកទៅដល់ព្រះស្វាមីនិងព្រះរាជបុត្រទាំងពីរ ដែលទឹងយំកេក្ដាយ ដើម្បីតារបៅ ។

<u>បញ្ជាក់គន្លឹះបញ្ហាចោទទី ១</u>

ដោយសង្ខេបមតិគន្លឹះបញ្ហាចោទទី ១ នេះទៅ យើងបានដឹងថា ៖ ផ្នែកនេះជាផ្នែកមួយ បញ្ជាក់អំពីសេចក្ដីស្នេហារវាងឪពុកម្ដាយនិងបុត្រធីតា តើមានកំរិតត្រឹមណា ? ។

បញ្ហាចោទទី ២ – តើការដោះស្រាយនូវឧបសគ្គ ទុក្ខព្រួយក្នុងពុទ្ធនិយម មានលក្ខណៈយ៉ាងណា ?

<u>ការដោះស្រាយ :</u>

តាមលទ្ធិពុទ្ធនិយម គួរអង្គពុំមានសមត្ថភាពនឹងដោះស្រាយ

អ្វីឡើយ ។ បើប្រសិនជាមានបញ្ហាវិបត្តិជាឧបសគ្គកើតឡើងចំពោះតួអង្គ គឺបុណ្យនោះទេ ដែលមកជួយដោះស្រាយនូវឧបសគ្គទាំងនោះ គឺផលល្អដែលបានកសាងពីអតីតជាតិ ។

បើពុំនោះសោតទេ នឹងមានអន្តរាគមន៍នៃទេវៈទាំងឡាយដើម្បីជួយដោះស្រាយនូវវិបត្តិអ្វីមួយ ។ ។ តួអង្គទុកដូចជាគ្រឿងចក្រ ហើយដែលត្រង់កំសនានោះទេ ដែលលើកទុកលើកដាក់ទៅតាមផលល្អនឹងផលអាក្រក់ ។

<u>បញ្ជាក់</u> : ការដោះស្រាយនូវឧបសគ្គ បញ្ហាស្មុគ្រស្មាញ ឬសេចក្តីទុក្ខព្រួយក្នុងលទ្ធិពុទ្ធនិយម ពុំដូចជាការដោះស្រាយនៅក្នុងលទ្ធិព្រាហ្មណនិយមឡើយ ។ ព្រោះប្រសិនបើគេត្រូវការដោះស្រាយនូវវិបត្តិអ្វីមួយ ។ គេច្រើនជាដាច់ខាតយកបំបាំងមកធ្វើជាធំ ។ បានសេចក្តីថា ៖ មានតែសង្គ្រាមតែប៉ុណ្ណោះ ដែលអាចធ្វើឲ្យគេរកផ្លូវដើរទៅរួច ។ ឧទាហរណ៍ដូចជារឿងរាមកេរ្តិ៍-រឿងទិព្វសង្វារ ឬរឿងមហាភារតជាដើម ។

បញ្ហាទី ៣ - ហេតុអ្វីបានជាក្រុងសុគមិត្រវេកបុត្រទីងមហេសីពុំឃើញ ?

<u>ការដោះស្រាយ</u> បានជាព្រះបាទក្រុងសុគមិត្រ វេកបុត្រទីងមហេសីពុំឃើញព្រោះ ៖

- នៅក្នុងរឿងយើងឃើញថា : ក្រុងសុគមិត្របានត្រឡប់មកវេកមហេសីពុំឃើញទ្រង់សោយសោកា, ក្រោយពីជីងស្មារតីឡើងវិញ, ព្រះអង្គក៏ត្រឡប់ទៅវេកមហេសីវិញ តែទ្រង់រកពុំឃើញទៀត ។ ក្រុងសុគមិត្រទ្រង់វិយោគលុះដល់សន្ធប់ ។ ដឹងខ្លួនកាលណា ក៏ធ្វើដំណើរតទៅមុខទៀតដោយឥតទីដៅ ។

- ការដែលព្រាត់ប្រាស់ពីរយាទីងបុត្រនោះ គឺដោយពៀរវេរាផលសាក្រក់តាមមកផ្តន្ទា ហើយដែលក្រុងសុគមិត្រត្រូវ

តែទទួលផលជាប់ខាត ។ ដូចជានៅក្នុងវគ្គទី ២ ទំព័រទី ៦ អ្នកនិពន្ធបានបញ្ជាក់ថា ៖

«ព្រះអង្គវង្សទុក្ខទល់ ហេតុអំពល់អំពើពៀរ
កាលស្ដេចយកបក្សី សត្វសេកសោមឲ្យបុត្រា ។
ទាំងតីយកមកលេង ពិតពុំក្រែងពៀរវេរា
ហើយបោចរោមសារិកា បីទង់ទើបឈាមប្រាលផ្ដៅ ។
យកកូនពីសំបុក មេវាទុក្ខពេកក្ដាត់ក្ដៅ
ហើយយកទៅទុកនៅ ផែលគួចដើមពីមុនវៃ »

បានសេចក្ដីថា ៖ កាលស្ដេចយកបក្សីសត្វសេកសោមឲ្យបុត្រលេង ទាញទង់បោចស្លាប ចេញឈាមប្រាលផ្ដៅ ហើយក្រុងសុភមិត្រ បានយកសត្វនោះទៅទុកក្នុងសំបុកដូចដើមវិញ ។ គឺកម្មពៀរវេរានេះឯងដែលផ្ដល់ឲ្យផលអាក្រក់ទាំឲ្យរកបុត្រនឹងមហេសីពុំឃើញ ។

តែបើយើងនិយាយអំពីនិពន្ធវិធីវិញ យើងឃើញថា:

ដើម្បីឲ្យរឿងក្រុងសុកមិត្រនេះទៅជារឿងកំសត់ ក្នុងលទ្ធិពុទ្ធនិយម អ្នកកវីនិពន្ធគេបានប្រើនូវកលហស្ត្ររបស់គេក្នុងការនិពន្ធតែង ៗ អាស្រ័យហេតុនេះ បានជាគេត្រូវឲ្យក្សត្រទាំង ៤ អង្គនេះព្រាត់ប្រាស់គ្នា ដើម្បីឲ្យស្របទៅតាមកម្មពៀរនៃរឿងទាំងមូលនេះផង ៗ

ម្ល៉ោះហើយការកំសត់ក៏កើតមានឡើង ដោយធ្វើឲ្យព្រះបាទក្រុងសុកមិត្រកេបុត្រ-កេមហេសីមិនឃើញ ៗ

បញ្ហាបន្ទាប់បន្សំ — អំពីលក្ខណៈតួអង្គក្នុងចល់នាទី ២

១– <u>ក្រុងសុកមិត្រ</u> :

–(ទំព័រ ១៣ ខ្សែ ៩) គ្រាន់តែឮថាព្រះអនុជក្សត់ ក្រុងសុកមិត្រទ្រង់ក្រោធ ក្តៅថ្ងើម ស្ទើរបែកឧរា ហើយមាននេត្រាព្រាលដូចអគ្គី ៗ

– (ទំព័រ ២០ ខ្សែ ១) មកដល់ឆ្នេរសមុទ្រមហានទី ក្រុង

សុគមិត្រគិតភ័យ ទ្រង់សោយសោកយ៉ាងខ្លាំង ៗ

– (ទំព័រ ២៤ វគ្គ ១) ដោយការល័យបុត្រនឹងមហេសី ក្រុងសុគមិត្រសោយសោកដល់សន្លប់ ៗ

**សេចក្ដីបញ្ជាក់ :**

ការសោក, ការគិតភ័យទាំងអស់នេះ សុទ្ធតែជាលក្ខណៈនៃមនុស្សធម្មតា ៗ ដែលមិនខុសពីរឿងព្រាហ្មណនិយម ដែលមានព្រះពមជាអាទិទេព ក៏គង់ប្រែទៅជាមនុស្សភាពនៅពេលខ្លះ ៗ ដែរ ។

ដូច្នេះ ទុកជារឿងព្រាហ្មណនិយមក៏ដោយ ឬពុទ្ធនិយមក៏ដោយ ក៏តួអង្គឯកពុំអាចស្ថិតនៅជាតួអង្គអប្បរិយៈរហូតដល់ចប់ដែរ ៗ ព្រោះថា : រឿងទាំងនោះគឺជាតួអង្គរបស់មនុស្ស ដែលបិតនៅក្នុងសង្គមមនុស្ស បានប្រឌិតនិពន្ធតែងឡើង ៗ

**២– ជ័យទត្ត ជ័យសែន**

កុមារទាំងពីរនេះ គិតតែពុំភ័យខ្លាច កាលបើឃើញ ក្រុមមច្ចាសាកស្បូរ ។ មិនដូចជាបទុមវង្សក្រុមមរណា មានភាសោះ ដែលមានបិតុក្ខាហានដ៏មុះមុត ។ បើនិយាយពីព្រះជន្មនៃកុមារ ទាំងពីរនេះវិញឃើញថា : មានព្រះជន្មស្មើគ្នាយ៉ាងពិតប្រាកដ ចំពោះកុមារជ័យសែន ។

៣- នាងកេសរី :

នាងកេសរី មានលក្ខណៈជាកន្សែងសារពេជ្ជ ដែលមាន សេចក្ដីស្មោះត្រង់ ស្វាមីភក្ដិចំពោះស្វាមី ។ នាងបានឆ្លើយតប ទីងនាយកេត្រាដោយអាចទន់ក្លន់ ហើយឆ្លើយប្រាប់តាមត្រង់ ថា : នាងមានស្វាមីហើយ ។

ឃ្លាភ្ជាប់សេចក្ដី – តាមការសង្កេតរបស់យើងក្នុង ចលនាទី ២ នេះ ឃើញថា : ការព្រាត់ប្រាស់របស់ក្សត្រទាំង ៤ នេះ គឺ មកតែពីកម្មពៀរវេរាដែលបានបង្កពីអតីតជាតិតែប៉ុណ្ណោះ ។

តែយើងអាចចោទសួរថា តើការព្រាត់ប្រាស់នេះមានហេតុទោ ឬ ? ត្រង់នេះយើងសូមពន្យល់នឹងអត្ថាធិប្បាយនៅក្នុងបលនា ទី ៣ តទៅទៀត ។

x x x

## បលនាទី ៣

បញ្ហាចោទទី ១ – ហេតុអ្វីបានជាក្រុងសុគម៌ត្រ បាន
សោយរាជ្យនៅនគរតក្កសីលា ?

**ការដោះស្រាយ :**

ដូចជាយើងបានបញ្ជាក់មកហើយថា : គឺ ដោយសារផល បុណ្យដែលទ្រង់កសាងអំពីជាតិមុន ទើបបានផ្តល់មកក្នុងជាតិ នេះ ឲ្យទ្រង់បានសោយរាជ្យនៅនគរតក្កសីលានេះ ។ គឺ

ដោយសារព្រេងវាសនា ដែលក្រុងសុភមិត្រធ្វើដំណើរមកបំនគរតក្កសិលា, ហើយដែលជាផលនៃអំពើល្អ បាននាំឲ្យអ្នកនគរនោះ ធ្វើពិធីផ្សងបុស្សរថមកយានស្តេចឲ្យទៅគ្រងរាជ្យនៅនគរនោះ ។

យើងដឹងថា : ក្នុងការដែលក្រុងសុភមិត្រទទួលនូវរាជសម្បត្តិនេះ គឺមិនមែនដោយសារមធ្យោបាយ ការប៉ុនប៉ង ឬមានសមត្ថភាពក្នុងការតស៊ូអ្វីឡើយ (ដូចជារៀនមាយាស្រីជាដើម ដែលបេះប្រើមធ្យោបាយ ទីងប្រាជ្ញា ផ្សេង ៗ ដើម្បីជួយសង្គ្រោះជីវិតរបស់ខ្លួន) គឺដោយសារព្រះអង្គទទួលផលល្អអំពីជាតិមុន ហើយជាតិក្រោយនេះ ក្រុងសុភមិត្រត្រូវតែទទួល ទ. ខ្សែ ២ ទំព័រ ១៥ (ជាអស់នេះឯង) ត្រង់នេះគួរយើងធៀបប្រៀបទៅនឹងព្រះបាទវេស្សន្តរ ដែលស្តេចបេតកាស្ត្រនៅមាតុលនគរ បានថ្វាយរាជសម្បត្តិបំពោះព្រះអង្គ មានព្រះទ័យជ្រះ

ថ្វាទៅសាជ័ព្រះផ្សងក្នុងគិរីវង្កត ។

បញ្ហាចោទទី ២- មតិនិយមក្នុងការផ្សងបុស្សបុថ

ការដោះស្រាយ :

ដើម្បីជ្រើសរើសអ្នកមានបុណ្យ គេធ្វើពិធីផ្សងបុស្សរថ ហើយបើបុស្សរថនោះទៅឈប់ចំពោះមុខបុគ្គលណា គេសន្មត់ថាបុគ្គលនោះទុកជាអ្នកមានបុណ្យ ហើយត្រូវបានឡើងគ្រប់គ្រងនគរ ។ នេះបង្ហាញឲ្យឃើញថា : ទោះជារឿងក្រុងសុភមិត្រជារឿងព្រេងនិទានសុទ្ធសាធក៏ដោយ ក៏នៅតែមានបញ្ហាទាក់ទងទៅនឹងប្រពៃណីទំនៀមទម្លាប់តាមលទ្ធិព្រាហ្មណ៍ដែរ ។ បានសេចក្ដីថា : ដោយអ្នកករនិពន្ធរឿងនេះ ពុំទាន់ផ្ដាច់ឲ្យជ្រះស្រឡះនៅឡើយ ពីឥទ្ធិពលព្រាហ្មណ៍និយមដែលចូលមកលុកលុយកាលពីជំនាន់មហានគរ, សម័យនគរទីនឹងបុរីនគរនោះឯង ។

ក្នុងការប្រទក្សិណ ៣ ជុំនោះគេ

- ប្រទក្សិណពីស្តាំទៅឆ្វេង សម្រាប់សួស្តីមង្គល

- -ជ- ពីឆ្វេងទៅស្តាំ ចំពោះវត្ថុជាទីរពុក

ការលាះអាល័យ ។

បញ្ហាចោទទី ៣ ហេតុអ្វីបានជាក្រុងសុគមិត្រមិនស្គាល់បុត្រ ?

ការដោះស្រាយ : មូលហេតុដែលបណ្ដាលឲ្យក្រុងសុគមិត្រមិនស្គាល់បុត្រ មានដូចតទៅ ៖

មូលហេតុទី ១ – ដូចយើងបានបញ្ជាក់ក្នុងចលនាទី ១ ឬទី ២ រួចមកហើយ ការព្រាត់ប្រាស់ ការសោយទុក្ខវេទនា ។ល។ របស់ក្រុងសុគមិត្រនិងព្រះរាជវង្សនេះ គឺបណ្ដាលមកពីកម្មពៀរវេរារបស់ព្រះអង្គ ។ ហេតុនេះដោយសារតែអំពើបាបទាំងនេះហើយ ដែលធ្វើឲ្យព្រះទ័យមានមិច្ឆាបថ ចំពោះ

ក្រុងសុកមិត្រដែលបណ្ដាលមិនឲ្យស្គាល់បុត្របានថែមទៀតៗ ដូចជាអ្នកនិពន្ធបានបញ្ជាក់ថា ៖ ទំព័រ ២៥ ក្នុងវគ្គ ២ :

„ហេតុបាបបាំងឲ្យត្រឃ្លាន　　ពីបុរា អាកឲ្យជ្រើនគ្រា
នឹងឱយរងវេរា　　ផរាបរៀងរាល់សព្វជាតិ ។
ស្តេចភ្លាំងភ្លេចពូជព័ណ៌　　ពិតពុំស្គាល់បុត្រឯងអាទ៌
ស្តេចស្គាល់មានមារយាទ　　ផ្តាច់បម្រើត្រូវព្រះទ័យ" ។

មូលហេតុទី ២ — តែបើតាមមតិនិយមក្នុងលោកយើងវិញ គេពោលថា ហេតុដែលបណ្ដាលឲ្យក្រុងសុកមិត្រមិនស្គាល់កូននេះ ដោយមកពីព្រះអង្គព្រាត់យូរពេក គឺរហូតដល់ទៅជាង ៧ ឆ្នាំ ។ ម្យ៉ាងទៀតហើយអាចឲ្យព្រះអង្គពុំចាំមុខបានឡើយ ។ ព្រោះតាមធម្មតាក្មេង (សិក្សាតាមចិត្តសាស្ត្រ) តែងតែធាប់ផ្លាស់ណាស់ ព្រោះនៅវ័យដែលកំពុងត្រូវការទទួលនូវសេចក្តីកើតធាត់ធំ ដកកំពស់ផ្លាស់ប្តូរផង ។

មូលហេតុទី ៣ — ដោយការព្រាត់ប្រាស់យូរមកហើយផង ហើយគាប់ជួនជាព្រានទូលទៀតថា : ជាបុត្ររបស់ខ្លួន នោះ ព្រះអង្គ ក៏ពុំមានព្រះទ័យចាប់អារម្មណ៍ដល់រឿងរបស់ព្រះអង្គ បន្តិចឡើយ ។

ត្រង់នេះហើយដែលធ្វើឲ្យព្រះអង្គពុំអាចស្គាល់ ជ័យសេន-ជ័យទត្ត ដែលព្រានយកទៅថ្វាយនោះថាជាបុត្ររបស់ព្រះអង្គបានឡើយ ។

បញ្ហាចោទទី ៤ — ហេតុអ្វីបានជាព្រះនាង កេសនី
ស្គាល់កុមារទាំងពីរជាបុត្រ ?

ការដោះស្រាយ : យើងដឹងថា ក្នុងគ្រានោះព្រះបាទក្រុងសុគមិត្រ បានធ្វើពិធីជប់លៀងមួយដល់នាយគេត្រាទាំងឡាយ ដែលបានរើសព្រះនាងកេសនី ហើយដែលបានយកនូវផ្កាយផ្សេង ៗ ទៅថ្វាយព្រះអង្គដើម្បីជាកិត្តិយស ។

ដោយពុំមាននរណាជាទីទំនុកទុកព្រះទ័យ ព្រះអង្គក៏ចាត់មហាតួកទាំងពីរគឺ ៖ ចៅស័យសែន និង ជ័យទត្ត ឲ្យទៅចាំយាមសំពៅរបស់នាយកេត្រាទាំងនោះ ។ ទេសកាលអ្វីដែលនាំឲ្យកុមារទាំងពីរនេះ ទៅចាំយាមចំសំពៅដែលនាងកេសរីនៅក្នុងទីនោះ ជាពិសេសទៅទៀត គឺនៅក្នុងកាលរាត្រីនោះព្រះនាងកេសរី បានសោយសោកថ្ងូររៀបរាប់ស្រណោះដល់បុត្រនិងព្រះស្វាមី ដែលនាំឲ្យជ័យសែនជាបងឮនូវទំនួញនោះ ហើយដាស់ជ័យទត្តជាប្អូន ដើម្បីនិយាយអំពីការព្រាត់ប្រាស់ពីមាតាបិតាដែរ ។ កុមារបានពោលឈ្មោះនគរបម្បាកបូរ, ឈ្មោះមាតាកេសរី, បិតាក្រុងសុភមិត្រ ដែលនាំឲ្យព្រះនាងកេសរីស្គាល់ជាក់ថាជាពជបុត្ររបស់ព្រះនាងពិតប្រាកដ ។

បញ្ហាចោទទី៤ — ការពោលប្រកាន់របស់ពួកកេត្រា

ចំពោះកុមារថា : កុមារនេះស្រឡាញ់

ប្រពន្ធនាយគេត្រា ដែលជាម្ដាយឯងនោះ

តើសមហេតុសមផលឬទេ ?

ការដោះស្រាយ ៖ យើងដោះស្រាយតាមមតិបែបគេទៅនេះ ៖

មតិទី ១ បើតាមលទ្ធិ ឬ ទ្រឹស្ដីពុទ្ធនិយម ការចោទប្រកាន់របស់នាយគេត្រាចំពោះកុមារនេះសមហេតុសមផលណាស់ ព្រោះក្នុងលទ្ធិនេះ ត្លុកនៃស្រាវពេជ្រមិនអាចក្លាយទៅជាចាស់ជរាឡើយ ។ បានសេចក្ដីថា: បើនៅក្រមុំ គឺនៅតែក្រមុំរហូតហើយមានរូបឆោមល្អថែមទៀត ។ ហេតុនេះហើយបានជាពួកគេត្រាមានការភ័ន្តច្រឡំបាន ដោយកុមារនេះជំទង់ហើយមើលទៅព្រះនាងកេសរទីក៏នៅក្មេងដែរ ។ ម្ល៉ោះហើយក៏ចោទថា កុមារនេះស្រឡាញ់នាងកេសរទីទៅ ។ ដូចជារឿងហង្សយន្ដជាភស្តុតាងស្រាប់ ។ ព្រោះថា: ចៅក្រឹស្នាមិនព្រមស្រឡាញ់នារី ឬបុត្រីស្ដេចណាសោះ ។ ដល់ទៅ

ឃើញនាង បទុមកេសរ ដែលជាមាតារបស់ឯង ក៏មានចាប់ចិត្ត ស្រឡាញ់ភ្លាម ៗ ចុះបើបទុមកេសរមានវ័យចាស់ជរាវិញ ប្រហែលជាចៅក្រឹស្នាមិនទៅបេតីមេត្រីឡើយ ។

បើតាមមតិរបស់លោក ញ៉ុក-ថែម វិញលោកបានបញ្ជាក់ថា៖ ទោះជាតួអង្គកនៃរឿងសារពេជ្ញក៏ដោយ គង់តែប្រែប្រួលដូចជាមនុស្សធម្មតាដែរ ព្រោះថាមនុស្សគ្រប់រូបសុទ្ធតែ អនិច្ចំ ទុក្ខំ អនត្តា ៗ តែលោកបានបញ្ជាក់ទៀតថា: មានតែនាងវិសាខា ១ ប៉ុណ្ណោះទេ ដែលពុំមានប្រែប្រួលនូវវ័យ រូប ឬ សោភ័ណឡើយ ៗ ក្រៅពីនោះទៀត មានតែទេវធីតា ទេវបុត្រដែលមិនប្តូរនូវរូប វ័យ ដែរ ៗ

- លោកបានបញ្ជាក់ទៀត ចំពោះរឿងហង្សយន្តថា៖ រឿងនេះពុំពេញជាលក្ខណៈពុទ្ធនិយមឡើយ ។

រួមយោបល់ទៅ៖ តាមមតិខ្ញុំយល់ឃើញថា: អ្នកកវី

និពន្ធរឿងសុភមិត្តក៏ដោយ ឬរឿងហង្សយន្តក៏ដោយ ប្រហែលជានឹកឃើញនូវរូបសោភ័ណមិនប្រែប្រួល របស់នាងវិសាខានេះ ហើយបានជាលើកយកតួអង្គកន្សែងសារពេជ្ញ ទៅឱ្យមានរូបសោភ័ណមិនប្រែប្រួលដូចជានាងនោះដែរ ។

មតិទី ២— តែបើយើងដោះស្រាយតាមបែបទេវនិយម ឬលោកិយនិយមវិញ យើងឃើញថា : ការចោទប្រកាន់ពួកគេគ្រានេះពុំសមហេតុសមផលសោះ ។ ព្រោះធម្មតា ម្ដាយដែលបង្កើតកូនមកហើយ តែងតែមានវ័យច្រើនលើស យ៉ាងហោចណាស់ក៏ពីរឬបីតំណដែរ ។ មិនគួរណាឡើយពួកគេគ្រាចាំងនេះក័នច្រឡំបានសោះ ។ ហើយម្យ៉ាងទៀតចៅជ័យសែនជាបងទើបតែមានអាយុប្រហែលជាង ១០ ឆ្នាំសោះ ។ ហេតុនេះ តើយើងអាចចោទថា គ្នាមានសេចក្ដីស្នេហាចំពោះ

ព្រះនាងកេសនី (ឬតាមមតិនិយមនៃពួកកេត្រា) ជាជាប្រពន្ធរបស់នាយកេត្រាបានដែរ ?

– តែគេអាចឆ្លើយវិញថា : ដោយនៅពេលនោះជាពេលពន្លឺដែលពុំអាចឲ្យយើងឃើញច្បាស់ ។ ម្ល៉ោះហើយពួកកម្មករទាំងនោះស្មានថាកុមារនេះ ទៅស្រឡាញ់ចាប់ឲបប្រពន្ធនាយកេត្រាមែន ។

ការដោះទទឹងដោះស្រាយរបស់គេនេះក៏ត្រូវម្យ៉ាងដែរ ។ តែយើងដោះទស្សនៈគេទៀតថា : នៅពេលពន្លឺចុះ ជាពុំអាចដឹងច្បាស់, ចុះដល់ភ្លឺហើយម្ដេចក៏មិនរិះរិចឲ្យមើលលក្ខណៈ មើលបុគ្គល មើលមាឌរបស់គ្នា ដោយប្រៀបធៀបទៅព្រះនាងកេសនីផង – តែគេថា : ទេ ! នៅពេលដែលស្ដេចឲ្យយកទៅសម្លាប់នោះ គឺនៅពេលយប់ដែរ ។ បើគេឆ្លើយក៏ត្រូវដែរ តែៈនៅពេលដែលព្រាហ្មណ៍ សូមព្រះបាទគ្រុងសុកមិត្រឲ្យទុក

ជំនុំជំរះនោះ ហើយដែលនៅចំពោះព្រះភក្ត្រផ្ទាល់របស់ព្រះបាទក្រុងសុភមិត្រ – គួរណាស់តែព្រះអង្គក៏ដោយ ឬអស់មុខមន្ត្រីទូទៅក៏ដោយ ក៏គប្បីបេះគិតពិចារណាបន្តិចហើយ ទុកជាព្រះបាទក្រុងសុភមិត្រ ពុំទាន់សួរនូវរឿងហេតុរបស់កុមារទាំងពីរនេះក៏ដោយ ។ តែផ្ទុយទៅវិញ លើកលែងតែព្រាហ្មណ៍បុរោហិតតែម្នាក់ប៉ុណ្ណោះ សុទ្ធតែជឿថាកុមារនេះ បានទៅស្រឡាញ់ប្រពន្ធនាយកេត្រាមែន ។

ត្រង់បញ្ហាទី ២ នេះ យើងឃើញថាការចោទប្រកាន់នេះពុំសម ហេតុសមផលសោះ ។

បញ្ហាចោទទី៦– ហេតុអ្វីបានជាព្រះបាទក្រុងសុភមិត្រ ប្រើពេជ្ឈឃាតឲ្យយកកុមារ ទៅសម្លាប់ ?

ការដោះស្រាយ : ត្រង់បញ្ហាចោទសួរនេះ យើងអាចដោះស្រាយបាន ២ ខ ដូចតទៅ ៖

១– បានជាព្រះបាទក្រុងសុភមិត្រប្រព្រឹត្តចំពោះកុមារដូច្នេះ ព្រោះតាមធម្មតា ខ្លួនជាស្តេចផែនដី កាលបើការពារនូវសេចក្តីអសន្តិសុខចំពោះចៅពុំបាន នោះគេទុកជាស្តេចគ្មានសមត្ថភាពគ្រប់គ្រងនគររបស់ខ្លួន ។ ម្យ៉ាងហើយដើម្បីការពារកិត្តិយសទាំងអស់នោះ មានតែប្រើពេជ្ឈឃាដឲ្យយកកុមារទាំងពីរនេះទៅសម្លាប់ចោល ដើម្បីសងឲ្យសមតាមការប្រព្រឹត្តរបស់កុមារទាំងពីរដែលនាំអាប់កិត្តិយសដល់ព្រះអង្គ ។

២– តែបើដោះស្រាយ តាមមនុស្សនិយមវិញ ឃើញថា: ការបង្គាប់ឲ្យពេជ្ឈឃាដយកកុមារទាំងពីរទៅសម្លាប់នេះ ដោយហេតុតែព្រះបាទក្រុងសុភមិត្រខ្វះនូវការពិចារណា ខ្វះ

វិចារណញ្ញាណ ហើយជាពិសេសទៅទៀត បញ្ហាយើងនឹងឃើញថា : គឺដោយសារព្រះបាទសុកមិត្រមានព្រះទ័យមោហៈខ្លាំងពេកទៅហើយ ជាពិសេស ដោយព្រះអង្គបង់ការពារឡូកិត្តិយសរបស់ព្រះអង្គផង ទើបព្រះអង្គប្រើអំណាចឲ្យសមទៅតាមកំហុសទាំងនោះ ៗ សេចក្តីតឡើងដែលទឹងការណែនាំរបស់ព្រាហ្មណ៍ទេ ទើបព្រះអង្គសព្វព្រះទ័យឲ្យយកកុមារនោះមកសួរកេហេតុផល ឲ្យសមទៅតាមលទ្ធិប្រជាធិបតេយ្យវិញ ។

បញ្ហាចោទទី ៧ - ហេតុដូចម្តេចបានជាព្រះបាទក្រុងសុកមិត្រ ស្គាល់កុមារទាំងពីរ ថាជាបុត្របង្កើត ?

ការដោះស្រាយ :

ត្រង់នេះយើងអាចធ្វើយបានភ្លាមថា បានជាព្រះបាទក្រុង

សុគមិត្រស្គាល់កុមារទាំងពីរថាជាបុត្រ ព្រោះកុមារនេះបានប្រាប់ឈ្មោះនគរដែលមាតាបិតារបស់ខ្លួនសោយរាជ្យ, ប្រាប់ព្រះនាមមាតាបិតា ៗ ម៉្លោះហើយដោយសារពត៌មានទាំងនេះ ព្រះអង្គជ្រាបថា ចៅជ័យសែន និងជ័យទត្ត គឺជាបុត្ររបស់ព្រះអង្គ ៗ

តែគេចោទសួរទៀតថា ៖ ហេតុអ្វីបានជាកុមារទាំងពីរនេះទៅប្រាប់ឈ្មោះនគរនឹងព្រះវរមាតាបិតាដូច្នោះ យើងអាចឆ្លើយបានថា ៖

– ព្រោះកុមារទាំងពីរខ្លាចស្លាប់ ៗ គេសួរទៀតថា: ចុះហេតុអ្វីបានជាកុមារទាំងពីរខ្លាចស្លាប់ ? មកដល់បញ្ហាចោទសួរត្រង់នេះ យើងដូចជាពិបាកឆ្លើយបន្តិច ៗ តែនុយស្របទៅតាមដំណើររឿង យើងសូមដោះស្រាយដូចតទៅនេះ ៖

– ហេតុដែលនាំឱ្យព្រះបាទក្រុងសុគមិត្រ ស្គាល់កុមារទាំងពីរថាជាបុត្រ ព្រោះកាលពីជាតិមុនព្រះអង្គបានយកកូន

សេកមកបោចកោយស្ទាបលេង ៗ តែដល់ក្រោយមកទ្រង់ក៏យកទៅដាក់ក្នុងសំបុកដើមវិញ ៗ ដូចជាអ្នកនិពន្ធបានពោលបញ្ជាក់ក្នុងខ្សែ ៤ ត្រង់ទំព័រ ២ ថា ៖

យកកូនពីសម្បុក　　　មេជាទុក្ខពេកក្តាត់ក្តៅ
ហើយយកទៅទុកនៅ　　　ដែលខ្លួចដើមពីមុននៃ ។

ដូច្នេះហើយ បានជាក្នុងជាតិនេះពៀរវេរាតាមផ្ដន្ទាធ្វើឲ្យក្រុងសុកមិត្រព្រាត់ប្រាស់គ្នាសិន ហើយដល់អស់កម្មពៀរ ក៏តម្រូវឲ្យព្រះអង្គបានជួបបុត្រនឹងភរិយារបស់ព្រះអង្គវិញ ៗ បានសេចក្តីថា ការជួបបុត្រក្តី ការជួបព្រះអគ្គមហេសីក្តី គឺមកតែពីកម្មពៀរវេរាអស់ជីវិតទៅ ហើយផលបុណ្យក៏បានមកសន្និតវិញតែប៉ុណ្ណោះឯង ។

បញ្ហាចោទទី៨ - បញ្ហាតួអង្គ (ព្រះបាទក្រុងសុកមិត្រ)

ការដោះស្រាយ :

១- ក្នុងការព្រាត់ប្រាសពីនគរ, ពីបុត្រនិងមហេសី ព្រះបាទក្រុងសុភមិត្រទ្រង់យំអាល័យបុត្រភរិយា ។ តែដល់ព្រះអង្គបានឡើងសោយរាជ្យនៅនគរតក្កសិលា ព្រះអង្គពុំមានព្រះទ័យនឹករឭកនឹងរិះរកមធ្យោបាយណា ដើម្បីទៅរកមហេសីនិងបុត្ររបស់ព្រះអង្គឡើយ ។ ត្រង់នេះបញ្ជាក់ឲ្យយើងឃើញថា ក្រុងសុភមិត្រមានលក្ខណៈដូចជាមនុស្សធម្មតា ។ គឺនៅពេលណាមានទុក្ខព្រួយមកដល់ ក៏ទឹកប្រែពន្លួន តែដល់បានសប្បាយស្រណុកសុខស្រួល ភ្លេចអស់នូវសេចក្តីវេទនា ការកំសត់តាំងពីមុន ហើយជាពិសេសភ្លេចដល់ទៅបុត្រនិងភរិយារបស់ខ្លួនទៀត ។ មតិអ្នកខ្លះបានពោលថា បានជាព្រះបាទក្រុងសុភមិត្របំភ្លេចអស់នូវបុត្រនិងភរិយាដូច្នេះ ព្រោះ ព្រះអង្គបានឡើងសោយរាជ្យ ហើយថែមទាំងមានស្នំក្មេង-ស្អាតយ៉ាង

កកកុញទៀត ។ ការប្តូរពីពោធិសត្វភាពទៅជាមនុស្សភាពវិញនេះ ហើយដែលយើងចាត់ទុកគម្ពីរនេះចូលទៅក្នុងពពួកអមនុស្សធម៌បានដោយសមហេតុសមផលជាពន់ពេក ។ តែបើតាមមតិរបស់លោក ញ៉ុក ថែម វិញ លោកបានបញ្ជាក់ថា ត្រង់បញ្ហានេះ អ្នកកវីនិពន្ធបង្ហាញកម្មផលរបស់គម្ពីរឲ្យកាន់តែច្បាស់លាស់ឡើងថែមទៀតតែប៉ុណ្ណោះ ។

២– បើយើងក្រឡេកមើលទៅក្នុងខ្សែទី ៣ វិញ យើងរឹតតែឃើញច្បាស់ទៀតថា ៖ ក្រុងសុគមិត្រមានលក្ខណៈខុសស្រឡះពីគម្ពីរពោធិសត្វ ព្រោះគ្រាន់តែនាយគេក្រាបទូលថា ៖ កុមារភាន់ពីបានប្រព្រឹត្តខុស ដោយហេតុថាទៅលបលួចស្រឡាញ់ប្រពន្ធរបស់ខ្លួន ទ្រង់ក៏ប្រើពេជ្ឈឃាដចាប់ចងយកទៅសម្លាប់ភ្លាមដោយឥតបានគិតរិះពិចារណា វិនិច្ឆ័យអ្វីបន្តិចឡើយ. បើពោលឲ្យខ្លីទៅទៀត ការប្តូរពីពោធិសត្វភាពទៅជាមនុស្ស

ភាពតែប៉ុណ្ណោះពុំមានគ្រប់គ្រាន់នៅឡើយ ។ ព្រោះថា៖ ព្រះបាទក្រុងសុតសោមត្រូវធ្លាក់ខ្លួនអន់ជាងមនុស្សធម្មតាទៅទៀត ។ ដូចជាព្រះរាមនៅក្នុងរឿងរាមកេរ្តិ៍ ខ្សែ ៧៧-៧៨-៧៩ ទំព័រ ៨០ ដែរ ។ ដែលពុំមានលក្ខណៈជាព្រះអាទិទេពភាព ឬជាមនុស្សភាពបន្តិចឡើយ ។

## បញ្ហាចោទទី ៤ – បញ្ហាសជាតិ.

ការដោះស្រាយ :

រឿងក្រុងសុតសោម គឺជារឿងដែលគេបញ្ចូលទៅក្នុងពួករឿងជាតក ។ បានជាថាដូច្នេះ ព្រោះថា៖ រឿងនេះដោះស្រាយតែពីបញ្ហាកម្មផល ហើយបើមានវិបត្តិអ្វីម្យ៉ាង ១ កើតឡើងចំពោះតួអង្គ ក៏យកតែកម្មផលពៀរវេរមកដាក់ពីមុខជានិច្ច ។

ម្យ៉ាងទៀត ក្នុងរឿងជាតកនិមួយ ៗ នៅចុងក្រោយបំផុត គេតែងតែមានការសេជាតិ គឺតួអង្គសំខាន់ ៗ ស្លាប់ទៅ ហើយនឹងកើតប្រកបដោយលក្ខណៈ ទីងគុណសម្បត្តិ គុណវិបត្តិតាមកម្មផលនៃការកសាង ។

ឯការសេជាតិនៅក្នុងរឿងគ្រុឌសុកម៉ិត្រនេះមាន៖

១- គ្រុឌសុកម៉ិត្រ —> ព្រះពុទ្ធអង្គ

២- នាងកេសរី —> ពិម្ពា

៣- ជ័យសែន —> រាហុល

៤- ជ័យទត្ត —> មហាអានន្ទ

៥- អសុកម៉ិត្រ —> ទេវទត្ត ។

សេចក្ដីសន្និដ្ឋាន:

ក្នុងរឿងជាតកនិមួយ ៗតែងតែមាន៖

១- ផ្តើមរឿង = ដំណាលពីអតីតជាតិនៃអង្គពោធិសត្វ ។

២- ដំណើររឿង= អត្ថាធិប្បាយអំពីពោធិសត្វ ទាំងសាង

សីលទាន ។ល ។

៣- ការសជាតិ = លទ្ធផលនៃការខំសន្សំបានបារមី ។

X X
X

# អត្ថរូប

## ក- បកាសរូប :

• ប្រភេទរូប :

ជារឿងបែបសាស្ត្រាល្បើង (គឺប្រលោមលោកបុរាណ) តែងជាពាក្យកាព្យផ្សេង ៗ មានបទកាកគតិ ·ព្រហ្មគីតិ·ភុជង្គលីលា·ពំនោល ជាដើម ។

២- អាស័យរូប

រឿងក្រុងសុភមិត្រនេះ បង្ហាញនូវកម្មផលផ្សេងៗ ដែលតួអង្គបានធ្វើពីអតីតជាតិ ហើយក្នុងបច្ចុប្បន្ននេះកម្មផលទៀតវេកវាំងនោះមកផ្តន្ទាទោសសងជំនួសវិញ ។

៣- ប្រធានរឿង -

ការផ្សងព្រេង និងការបណ្តាកាំសនារបស់ព្រះបាទក្រុងសុភមិត្រនឹងវង្សត្រកូល ឲ្យទៅតាមកម្មពៀរវេក ដែលពោរពេញទៅដោយការកំសត់ព្រាត់ប្រាស់ទុកសទីទៃ ៗ ។

២- បការរូប:

១- ទំងនរូប -

នៅក្នុងការតែងនិពន្ធនេះ អ្នកនិពន្ធបានប្រើពាក្យ :

- តែងកាព្យតាមបែបបាលី

ទំព័រ ១ វគ្គ ១២ : «អញវំអពី . . . . . ទុកគសាសនា»

– ប្រើពាក្យបាលី : ព្រះវរបិតាមាតា . អត្ថិ ។ ល ។

– ប្រើពាក្យសំស្រ្កឹតក្លាយ : ក្សត្រី ក្សត្រា ។

២– វចនារូប :

ក– ឃ្លាប្រយោគ :

ទោះជាឃ្លាបាលី ឬសំរាយជាកាព្យក៏ដោយ ក៏អ្នកកវីនិពន្ធ បានរៀបរៀងឡើងមានចុងចួនត្រឹមត្រូវ តាមបែបបទវេយ្យាករណ៍ដែរ ។

ឧទាហរណ៍ ក្នុងខ្សែ ( ទំព័រ ១ ) ៖

"នមាមិហំ ពុទ្ធសេដ្ឋំ លោកុត្តមោ គុណាគុណំ . . .

. . . . សទ្ធម្មោ គុណាករោ កតាលិនំ"

ខ– រូបារម្មណ៍ ៖

ពិតមែនតែអ្នកនិពន្ធតែងរៀងនេះជាពាក្យកាព្យក៏ដោយ ក៏

ប៉ុន្តែលោកពុំភ្លេចនូវរូបារម្មណ៍ខ្លះ ៗ ដែលជាសិល្បវិធីម្យ៉ាងធ្វើឲ្យរឿងទាំងមូលមានចលនា, មានសោភ័ណភាពឡើងដែរ ដូចជា ៖

- និម្មិតរូបារម្មណ៍ – ឧទាហរណ៍ :

កង់ខ្សែ ២ ទំព័រ ៨៖

“ស្តែងជាខ្ញុំឮសព្ទសត្វ យំស្រងាត់ក្នុងព្រឹក្សព្រៃ
សែនសោយសោកអាល័យ អាឡោះលង់ពត់ពេកក្តាត់”

- ឧបមាវិធី :

ឧទាហរណ៍ = ទំព័រ ១០ ខ្សែ ២៖

„ឱសព្ទសំឡេងព្រាត់ប្រាស់ឈ្មោលញី ដូចមេប្អូនស្រីប្រែប្រាស់ពីបង”

បានសេចក្តីថា ៖ កាលដែលក្រុងសុគមិត្រព្រាត់ប្រពន្ធកូនទៅ ព្រះអង្គត្រាច់ចរវង្វេងតែម្នាក់ឯងក្នុងព្រៃដ៏ស្ងាត់ជ្រងំ ៗ នៅពេលនោះហើយ ដែលព្រះអង្គបានទតឃើញនូវធម្មជាតិ

ចាំងឡាយ មានបលនារសរសើរ តែមានបក្សបក្សខ្វះព្រាត់ ឈ្មោលញី ដូចជាព្រះអង្គព្រាត់មហាសិទ្ធិបុត្រដែរ ។

គ- និពន្ធរូប :

១- កាយរូប :

គេផ្ដើមរឿងដោយបទនមស្សការព្រះរត្នត្រៃ ប្រាប់ឈ្មោះ អ្នកការនិពន្ធ និងប្រាប់ប្រភពនៃកំណើតរឿង ។

២- វណ្ណនារូប :

ក- ការបង្ហាញតួអង្គដោយអ្នកនិពន្ធ ៖

ឧទាហរណ៍ = ក្នុងខ្សែ១ ទំព័រ ១.

„តេរីកាលកប្បខណ្ឌទាំង . . , មានចេស្តាពេកកន្លង„

ខ- ការបង្ហាញរៀបរាប់ពីប្រាសាទ ៖

គឺការពិពណ៌នាអំពីប្រាសាទ អ្នកនិពន្ធរៀបរាប់ដោយ

ខ្លឹងឯងអំពីបន្ទាយប្រាំពីរជាន់អំពីប្រាសាទដំរើតឆាយ ដោយមានក្បូរក្បាច់ចេនាដំពិចិត្រ ៗ មានចំលាំងរូបចម្លាក់ផ្សេង ៗ ជាច្រើនទៀតផង ។

ក្នុងការធ្វើពិពណ៌នានេះ អ្នកនិពន្ធបានបេះយកពាក្យពេចន៍ គួរអក្សរផ្ទួន ៗ គ្នា សម្ងន់ប្រហែល ៗ គ្នា យកមកពិពណ៌នា ហើយដែលជាហេតុនាំឲ្យកើតរូបារម្មណ៍ឡើង ។

ឧទាហរណ៍ : ក្នុងខ្សែ ១ ទំព័រ ៥. . . , ៨

បន្ទាយប្រាំពីរជាន់ សឹងសរសើរព្រះបារមី

គ — ការបង្ហាញនូវបល នាលើកទ័ពធ្វើចំបាំង -

ចំណែកក្នុងការពិពណ៌នារៀបរាប់អំពីការលើកទ័ពនេះ អ្នកនិពន្ធបានប្រើបច្ចេកទេសល ដែលសមទៅតាមបែបបទកំណាព្យ ព្រមទាំងមានរបៀបរៀបរយអំពីបេនា ៗ អ្នកនិពន្ធបានប្រើ

នូវវេចនរូបវិធី បញ្ជាក់អំពីរូបភាពចលនាក្នុងពេលវេលា ដែលនាំឲ្យយើងឃើញហាក់ដូចជានៅនឹងភ្នែកស្រស់ ៗ ។

ឧទាហរណ៍ ក្នុងខ្សែទី ១ ទំព័រ ១២ :

ក្ងូររៀបគងសាកន្ទុំ    ស្មើរភ្ញូកប្រីភងណ្ដូរ

## ឃ– ការពិពណ៌នាអំពីធម្មជាតិ –

នៅក្នុងខ្សែទី ២ អ្នកនិពន្ធបានបញ្ចេញអំពីការពិពណ៌នាធម្មជាតិទូទៅទាំងអស់ដែលមានបិតនៅក្នុងព្រៃព្រឹក្សា ។ អ្នកនិពន្ធរើសយកដើមឈើណាដែលមានអក្សរដូចគ្នា សម្លេងប្រហែលគ្នា យកមកដាក់ជិត ៗ គ្នា ធ្វើឲ្យកើតជាកំណាព្យឡើង ដែលមានការចាប់ចុងចួនពីរោះរណ្តំគ្នា ជាទីចាប់អារម្មណ៍ក្រៃលែង ។

ក្នុងការរៀបរាប់អំពីធម្មជាតិនេះ អ្នកនិពន្ធបានរៀបរាប់ដោយវគ្គ ៗ ឬដោយពួក ៗ ដូចជា :

- ការរៀបរាប់ពីដើមឈើ.
- ការរៀបរាប់អំពីសត្វម្រឹគ.
- ការរៀបរាប់អំពីសត្វស្លាប.

- ក្នុងការរៀបរាប់អំពីដើមឈើ អ្នកនិពន្ធប្រមូលឈ្មោះឈើធំ ៗ ដាក់តម្រៀបគ្នា លាយជាមួយសម្ដែងពីរោះរណ្ដំធ្វើឲ្យមានបរិយាកាសកាន់តែរីករាយឡើង ៗ

- ក្នុងការរៀបរាប់អំពីសត្វម្រឹគ ឬសត្វស្លាបវិញ អ្នកនិពន្ធធ្វើឲ្យមានចលនារស់រវើក ហាក់ដូចកន្លែងនោះមាននៃនទែន ៗ

យោបល់បញ្ចប់ — ការពិពណ៌នាធម្មជាតិរបៀបនេះ ជាការប្រពៃហើយប្រសើរហើយ តែបើតាមរបៀបនិពន្ធសាស្ត្រនៃរឿងនេះទៅវិញ ឃើញថាមិនសូវសមសោះ ហើយអ្នកនិពន្ធសោតទៀត ក៏ហាក់ដូចជាពុំទាន់ចេះស្ទាត់នូវបច្ចេកទេសខាង

និពន្ធរូបវិធីច្បាស់លាស់ដែរ ព្រោះការរៀបរាប់នេះ មានការប្រឡូកប្រឡល់គ្នាដោយអន្ទើ ៗ ។ ឧទាហរណ៍ ដូចជាសត្វព្រៃនៅលាយជាមួយសត្វស្រុក — ឈើព្រៃលាយជាមួយឈើស្រុក ។ល។ ជាដើម ។ តែបើគ្រាន់តែសូរសព្ទសម្លេងនោះ ៗ ពិតជាពីរោះមែន ។

គ—នាដ្យវិធី

យើងឃើញថា ក្នុងចលនាទី ១ នាដ្យភាពបានកើតឡើង ដោយមានទំនាស់រវាងក្រុងសុគមិត្រ នឹងក្រុងអសុគមិត្រ គឺដោយសារបាបនេះទេ ដែលនាំឲ្យមានការទំនាស់រវាងក្សត្រទាំងពីរ គឺព្រះបាទក្រុងសុគមិត្រដែលទ្រង់ប្ដឹងបារមីដោយសារបុណ្យ ដល់ទ្រង់ត្រូវវិនាសហោលព្រះនគរទៅ គឺដោយសារតែបាបមានកម្មពៀរវេរាតែប៉ុណ្ណោះ ។

ដូច្នេះ គឺទំនាស់រវាងបាបនឹងបុណ្យនេះហើយ ដែលនាំឲ្យមានចលនានាដ្យភាពនេះឡើង ។

– ចំណាកនៅក្នុងបលនាទី ២ វិញ មានទំនាស់រវាងបុណ្យនឹងបាបនេះ បានឡើងកំរិតកាន់តែតឹងឡើង ៗ យើងឃើញថា នាដ្យសន្និវេសដែលនាំឲ្យយើងចង់ដឹងខ្លាំងឡើងៗ អំពីក្រុងសុគមិត្រថា ៖

– តើកែមហេសី - បុត្រ ឃើញប្ដីទេ ?

នាដ្យខណៈនោះ គឺ

– ក្រុងសុគមិត្រនាំមហេសីចូលសមុទ្រទទី -

– ព្រានល្បួងលោមកុមារទាំងពីរ ៗ

– នាយកេត្រាល្បួងលោមព្រះនាងកេសនី ៗ

<u>ប – សន្ទេហៈវិធី.</u>

យើងឃើញបលនាទំនាស់រវាងផលល្អនិងផល អាក្រក់នៅមានកំរិតខ្លាំងៗដែល ៗ ប៉ុន្តែបរិយាកាសបានដូរស្រាលបន្តិច ដោយផលល្អបាននាំឲ្យក្រុងសុគមិត្រ បានឡើងសោយរាជ្យ

ទៅនគរតក្កសីលា ។ ដែលនាំឲ្យយើងចង់ដឹងថា: តើព្រះអង្គបានជួបបុត្រភរិយាឬទេ ? តទៅទៀត សន្ទូហាវិធីនេះ ក៏មានកំរិតខ្លាំងឡើងទៅទៀត ដែលនាំឲ្យយើងបែកជា ៖

១– <u>សន្ទូហាវិធីកើតឡើងដោយកើតមកអំពីទាន់ខណៈ:</u>

– ព្រានយកកុមារទៅថ្វាយក្រុងសុគមិត្រ ដែលនាំឲ្យយើងចង់ដឹងថា: តើក្រុងសុគមិត្រស្គាល់បុត្រឬទេ ?

– នាយគេត្រានាំនាងកេសនីទៅដល់នគរតក្កសីលា តើជួបនឹងព្រះបាទក្រុងសុគមិត្រឬទេ ?

– ព្រះបាទក្រុងសុគមិត្រឲ្យយកកុមារទាំងពីរ ទៅសំឡាប់ តើស្លាប់ឬទេ ?

២– <u>សន្ទូហាវិធីដែលកើតមកអំពីការចង់ដឹង-សង្ស័យ :</u>

– តើក្រុងសុគមិត្របានជួបនឹងមហេសីឬទេ ?

– ក្រុងសុភមិត្រធ្វើទោសនាយកេត្រាប្អូន ។

៣– អត្តរូប :

ក្នុងរឿងនេះ  អ្នកនិពន្ធគេបានបញ្ចប់ដោយការជួបជុំនៃក្សត្រទាំង ៤ អង្គ និងការសជាតិនូវតួអង្គសំខាន់ៗ ។

ឧទាហរណ៍ ក្នុងខ្សែទី ៣ ទំព័រ ១៩, ខ្សែ ២ ទំព័រ ២០-២១។

X X
X

## អត្ថរស

ក– បញ្ចុករស :  បញ្ចុកសិល្បារម្មណ៍រស ឬ តម្លៃសំខាន់ដែលបិតនៅលើកាព្យសិល្បារម្មណ៍ ( Le poétique) ដែលថ្លែងរៀបរាប់អំពីដំណើររឿង  ហើយជាពិសេស  នៅពេលដែលអ្នកនិពន្ធពិពណ៌នារៀបរាប់ (Description) អំពី

ប្រាសាទនានាដែលប្រកបដោយពាក្យពេចន៍ទន់ភ្លន់ពីរោះ ៗ

ឧទាហរណ៍ នៅខ្សែ ១ ទំព័រ ១-២-៣-៤-៥-៦-៧-៨-៩ និង ១០ ។

១- វិសេសរស :

វិសេសសិល្បកម្មណាត្ករស ឋិតនៅលើប្រសាទសិល្បកម្មណាត្កដែលមាន ៖

១ នាដ្យភាព (Le dramatique)

គឺកើតឡើងដោយនាដ្យវិធីផ្សេង ៗ មាននាដ្យសន្និវេស (Situation dramatique) ជាដើម ។

ឧទាហរណ៍ : គឺដោយសារទំនាស់រវាងបុណ្យនិងបាបនេះ ហើយដែលនាំឱយមានចលនាតឹងតែងឡើង ៗ ត្រង់នេះយើងឃើញថាមាននាដ្យសន្និវេស ដែលនាំឱយយើងចង់ដឹងខ្លាំង អំពីព្រះបាទក្រុងតក្កសិលា : តើរកឃើញកូនប្រពន្ធឬទេ ?

ឧទាហរណ៍គឺ :

១- ព្រានល្បួងលោមកុមារទាំងពីរ ។

២— ទាយភេទព្រានល្បួងលោមមហេសី

- បលទាវំនាស់រក់នឹផលល្អនឹងភាគ្រក់ ទៅ ខកំរស្ទាំង ជាដែល ។ តែបរិយាកាសបានផ្លូវបន្តបរាវិញ ដោយព្រះបាទក្រុងសុភមិត្របានឡើងសោយរាជ្យនៅនគរតក្កសីលា ។ ហើយដែលនាំឲ្យយើងដឹងថា : តើព្រះបាទបានជួបនឹងមហេសីឬទេ ?

- ព្រានយកកុមារទៅថ្វាយព្រះសុភមិត្រ ដែលនាំឲ្យយើងចោទសួរថា : តើព្រះបាទក្រុងសុភមិត្រស្គាល់រាជបុត្រឬទេ ?

- នាដ្យសង្គិវេសមានកំរិតខ្លាំងដោយដំណើររឿងបិតទៅលើមិច្ឆាបាទ (erreur).

ឧទាហរណ៍ ព្រះបាទក្រុងសុភមិត្រឃើញបុត្រ ហើយ តែស្គាល់ថាជាបុត្ររបស់ព្រានទៅវិញ ។

ព្រះអង្គស្មានខុសទៀតថាៈ កុមារទាំងពីរទៅស្រឡាញ់ប្រពន្ធនាយភេត្រាមែន ម្ល៉ោះហើយក៏ប្រើឧបពេជ្ឈឃាតយកទៅសម្លាប់ ។

២- តាំសក់ (le pyrrhique)

*— កំសត់នេះលេចចេញពីនាដ្យភាព គឺចំណាស់រាជព្រះបាទក្រុងសុភមិត្រ និងអសុភមិត្រ ។ បានសេចក្ដីថា: គឺរាជបាបទឹងបុណ្យដែលសុភមិត្រធ្លាប់សាយភាយក្រៀមក្រៀនជាមួយទឹងមហេសីទឹងបុត្រ (ដោយសារបុណ្យរបស់ព្រះអង្គ) ស្រាប់តែត្រូវព្រាត់ប្រាសចាកសព្វរាជសម្បត្តិ គឺប្រាសាទ (ដោយសារអសុភមិត្រក្បត់) គឺដោយសារបាបរបស់ព្រះអង្គពីជាតិមុន ហើយជាតិនេះត្រូវតែទទួល ។*

*— ដោយព្រះបាទក្រុងសុភមិត្រត្រូវព្រាត់ប្រាសបុត្រភរិយា ។*

*— ដោយព្រះបាទក្រុងសុភមិត្រនាំមហេសីឆ្លងសមុទ្រ ។*

*កុមារយំសោករកព្រះជនក ជនី នាងកេសរីយំសោក*

ព្រះស្វាមី-កេបុត្រ មុននាយគេត្រាចាប់យកនាងទៅ ។ កំសត់មកពីការព្រាត់ប្រាស់គ្នាជាយូរមកហើយ ។ បានជួបគ្នាវិញ ។

## គ- សព្វរស :

សព្ទសិល្បារម្មសថិតនៅលើ ៖

១- សោភ័ណ (Le beau) គឺល្អ ៖

- គុណផ្នែកអត្ថន័យដែលបង្ហាញនូវហេតុផល នៃអំពើអាក្រក់ដែលខ្លួនបានប្រព្រឹត្តហើយ កម្មនោះវាវិលមកផ្តន្ទាវិញ ជាពិសេសទៅទៀត គឺបង្ហាញឲ្យឃើញថា : ការគិតតែពីអត្ត ហើយផ្តល់នូវទុក្ខវេទនាដល់មនុស្សទូទៅ នោះឃើញថា ពុំប្រសើរឡើយ ។ ដូចជាព្រះបាទក្រុងសុភមិត្រ នៅពេលដែលព្រះអនុជក្បត់ ព្រះអង្គពុំច្បាំងតបតឡើយ ដោយខ្លាចប្រជារាស្ត្ររបស់ព្រះអង្គស្លាប់ មានទុក្ខព្រួយលំបាក ។ល។

ជាដើម ដោយសារតែខ្លួនដណ្ដើមកផលសម្បត្តិគ្នាទៅវិញ ។

- ក្នុងផ្នែកវត្ថុរូប (វិធីតែងមានរបៀបពាក្យពេចន៍ជូនរណ្ដំ ផ្សំដោយសិល្បវិធីផ្សេង ៗ ។

២– អច្ឆរិយៈ (Le merveileux)

ការហែលឆ្លងនៃសមុទ្រនទី ដែលធ្វើឲ្យយើងជឿពុំបានទាល់តែសោះ ព្រោះការហែលឆ្លងទៅវិញទៅមកនេះ ហាក់ដូចជាត្រែកមួយដែលមានទំហំដ៏សមគួរដល់មនុស្ស ។

៣– លោកិយសច្ចៈ (Le rêel)

ពិតមែនតែរឿងក្រុងសុភមិត្រនេះ ជារឿងពុទ្ធនិយមក៏ដោយ ក៏កវីនិពន្ធបានធ្វើឲ្យលក្ខណៈរបស់តួអង្គពោធិសត្វក្លាយទៅជាលក្ខណៈរបស់មនុស្សពិត ។ ក្នុងការរស់នៅក្នុងសង្គមមនុស្ស ។

ឧទាហរណ៍ : ការទឹកប្រឡេតតាំងក្រុងអស្សុភមិត្រដែលមានចិត្តក្បត់ ការយំសោកអាណោះអាល័យដល់បុត្រភរិយាដែលព្រាត់ប្រាសទៅ ។ ការយល់ខុសក្ដីបរមនុស្សធម៌, ក្នុងរឿងយកបុត្រខ្លួនទៅសម្លាប់ ។

— ការក្បត់របស់ក្រុងអស្សុកមិត្រ ជាបញ្ហារបស់មនុស្សដែលអាចកើតមានឡើងក្នុងការលោភចង់ធំចង់សោយរាជ្យ ហើយដែលអាចមានរវាងបងប្អូនដូច្នេះ ។

មានបញ្ហាទំនៀមទម្លាប់ មានពិធីផ្សងបុស្សរថ ពិធីសូត្របម្រើនព្រះឥន្ទ្រ ជាដើម ដែលជាពិធីមានពិតប្រាកដក្នុងសង្គមមនុស្ស ។

— បញ្ហាដែលស្ដេចតូចតាច ត្រូវតែចុះចូលនាំស្លួយសារអាករ មកថ្វាយស្ដេចចក្រពត្រាធិរាជ ។

— ទោះជាការកែច្នៃនៃរឿងក៏មានចំណុចខ្លះ ៗ នៅក្នុងសង្គមមនុស្សលោក ។ ឧទាហរណ៍ : ទិព្វភាពស្រុកទេស ឈ្មោះគតរ ។ល។

# និដ្ឋានកថា

ពិតមែនតែរឿងក្រុងសុភមិត្តនេះជារឿងរបស់ព្រះសង្ឃនៅស្រុកឈៀងម៉ៃ ដឹកនាំបញ្ចូលមកក្នុងស្រុកទេសយើង ក៏អ្នកកវីនិពន្ធយើងប៉ិនប្រសប់ណាស់ ដោយយករឿងនោះមកនិពន្ធតែងឡើងឲ្យសមទៅតាមលក្ខណៈនៃរឿង បែបប្រទេសជាតិ ទំងឲ្យសមទៅតាមយក្ខណៈនៃរឿងជាតកធន៍ ដែលធ្វើឲ្យអ្នកស្រុក អ្នកអាន ទស្សនា ហើយជាពិសេសចំពោះពុទ្ធសាសនិក មានចិត្តជាប់អារម្មណ៍ជាគន់ពេក ។

– ចប់ –

# ប្រធាន

១- ចូរអ្នកសិក្សាអំពីលក្ខណៈដែលបញ្ជាក់ថា រឿងក្រុងសុភមិត្រជារឿងអក្សរសិល្ប៍មួយពេញលក្ខណៈ ។

២- ទ្រឹស្តីព្រះពុទ្ធសាសនា បានថែងថា "ធ្វើល្អ បានល្អ ធ្វើអាក្រក់ បានអាក្រក់" ចុះហេតុដូចម្តេចបានជាព្រះបាទសុភមិត្រដែលបានប្រព្រឹត្តតែអំពើល្អក្នុងបច្ចុប្បន្នជាតិ ត្រូវបានទទួលលទ្ធផលផ្ទុយទៅវិញ

ចូរអ្នកសិក្សាវែកញែកឲ្យយោបល់ ?

៣- ចូរប្រៀបធៀបកំសត់ក្នុងរឿងក្រុងសុភមិត្រ នឹងក្នុងរឿងទុំទាវ ។

៤- ចូរស្រង់ដោយអធិប្បាយវគ្គណាមួយ ក្នុងរឿងក្រុងសុភមិត្រដែលអ្នកយល់ថា អ្នកកវីនិពន្ធសរសេរល្អ ហើយថែមទាំងមានសារៈសំខាន់ទៅតាមសាច់រឿងថែមទៀតផង ។

៥– អ្នកខ្លះពោលថាៈ ព្រះបាទក្រុងសុកមិត្រជាអត្តទត្ថបុគ្គល ព្រោះនៅពេលដែលអសុកមិត្រជាប្អូនដណ្តើមរាជសម្បត្តិនោះ ព្រះអង្គបានភៀសចេញពីព្រះនគរជាមួយនឹងព្រះញាតិវង្ស ទុកឲ្យរាស្ត្ររស់នៅលំបាកវេទនា ក្រោមការជិះជាន់នៃក្រុងអសុកមិត្រ ។ (ចំពោះអ្នក តើយល់ដូចម្តេចវិញ ?)

៦– ថាៈ ‹‹ឱប្អូនអើយ វាកពៀរព្រងយើង ឯងដល់ហើយ ព្រលឹងបងអើយ កុំសោយសោកា›› ខ្សែ ១ ទំព័រ ៦ ។

ដោយសំអាងទៅលើពាក្យល្បងលោមរបស់ព្រះបាទក្រុងសុកមិត្រនេះ សូមអ្នកដោះស្រាយអំពីបញ្ហាកម្មផលក្នុងរឿងក្រុងសុកមិត្រ ។

៧– ពន្យល់អំពីកម្មពៀរក្នុងក្រុងសុកមិត្រ ទាំងឲ្យយោបល់ផ្ទាល់ខ្លួន ចំពោះទស្សនៈនេះ ។

៨– កំសត់ក្នុងរឿងក្រុងសុកមិត្រ

(មធ្យមសិក្សាប័ត្រ ឆ្នាំ ១៩៥៨)

៩- នាងកេសរីមានទុក្ខដោយសារកម្មផលក្នុងអតីតកាល នាងកាកីមានទុក្ខដោយបុព្វហេតុក្នុងបច្ចុប្បន្នកាល ។ តើការប្រៀបធៀបដោយតួអង្គទាំងពីរនេះ អាចបង្ហាញនូវសារសំខាន់ក្នុងអក្សរសិល្ប៍ខ្មែរឬទេ ?

១០- ការព្រាត់ប្រាស់នៅក្នុងរឿងក្រុងសុភមិត្រ ។

១១- តើការចោទប្រកាន់របស់នាយកេត្រា ចំពោះកុមារជ័យសែននឹងជ័យទត្តថា ស្រឡាញ់ប្រពន្ធនាយកេត្រា ដែលជាម្ដាយឯងនោះ (នាងកេសរី) សមហេតុសមផលដែរឬទេ ?

សូមដោះស្រាយនឹងពិភាក្សាឲ្យយល់

សូម.លោកអ្នកនាងរង់ចាំ :

# អត្ថបទវិជ្ជា រឿង - គោតកុលកុមារ

# - កាកី - ភមក្តើ៍

របស់អ្នកនិពន្ធ អុំ - មារឌី

នឹងចេញផ្សាយនៅពេលឆាប់ ៗ នេះ.ហើយ

ដោយ

បណ្ណាគារ ពន្លឺអក្សរសាស្ត្រ

បណ្ណាគារ ពន្លឺអក្សរសាស្ត្រ

ដែលធ្លាប់ទទួលអស់លោក-អ្នក-នាងដោយរាក់ទាក់នោះ សូមជំរាបជូនជាថ្មីថា ៖ ទីនេះសម្រាំងយកសៀវភៅសិក្សាបារាំង-ខ្មែរល្អៗ ទុកជូនលោក-អ្នក-នាងឲ្យបានពេញចិត្ត ។

បណ្ណាគារនេះ មានប្រដាប់ប្រដាសិស្ស-គ្រូ សម្ភារៈការិយាល័យ - ទស្សនាវដ្ដីខ្មែរ-បារាំងសម្រាប់យុវជន និងប្រលោមលោកគ្រប់មុខ ។

សូមកុំភ្លេច អញ្ជើញទាក់ទងតាមត្រូវការ ។


បណ្ណាគារ ពន្លឺអក្សរសាស្ត្រ

១៣៨ វិថីព្រះបាទសីហនុ ភ្នំពេញ

បណ្ណាគារ ពន្លឺអក្សរសាស្ត្រ
១៣៨-វិថីព្រះបាទសីហនុ ភ្នំពេញ

បោះពុម្ពហួរ-មួយ

តម្លៃ ១៨រៀល